# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ ១: តារាងបែងចែកប្រភេទសំណល់រឹង

| ល.រ | ប្រភព និងប្រភេទសំណល់ |
|---|---|
| ១ | **សំណល់តាមផ្ទះ** |
| | - សំណល់ផ្ទះបាយដែលកើតឡើងតាមរយៈសកម្មភាពដាំស្ល<br>- សំណល់ប្លាស្ទិកក្រោយពេលដែលគេឈប់ប្រើប្រាស់សំរាប់វេចខ្ចប់<br>- សំណល់ក្រណាត់ដែលកើតឡើងតាមរយៈសមកម្មភាពកាត់ដេរបន្តិចបន្តួច ឬកន្ទបសំរាប់ជូតចានឆ្នាំង ឬជូតផ្ទះជាដើម<br>- សំណល់សំលៀកបំពាក់ចាស់ៗដែលគេឈប់ប្រើប្រាស់<br>- សំណល់លោហៈ*<br>- សំណល់កែវ មានដប កែវបែក កញ្ចក់ជាដើម<br>- សំណល់ក្រដាស ដែលកើតពីការវេចខ្ចប់ កាសែតអាន ។ល។<br>- សំណល់ក្រដាសកាតុង<br>- សំណល់ឈើមិនមានលាបថ្នាំ ដូចជាគ្រឿងសង្ហារឹមដែលបាក់បែកដែលគេឈប់ប្រើ<br>- សំណល់ឈើមានលាបថ្នាំ*<br>- សំណល់ស្បែក ដូចជា ទ្រនាប់ជើង ខ្សែក្រវាត់ កាបូបដៃ ឬកាបូបយួរដែលឈប់ប្រើប្រាស់ ។ល។<br>- សំណល់កៅស៊ូ ដូចជាកៅស៊ូកង់ កៅស៊ូកង់យានយន្ត និងសំណល់ផ្សេងទៀតដែលធ្វើអំពីកៅស៊ូ ។ល។<br>- សំណល់ថ្មពិល*<br>- សំណល់អាគុយ*<br>- សំណល់គ្រឿងអគ្គិសនី*<br>- សំណល់គ្រឿងអេឡិកត្រូនិច*<br>- សំណល់បៃតង ដូចជាបន្លែ ផ្លែឈើ ស្មៅ មែកឈើ ស្លឹកឈើ ។ល។<br>- សំណល់ព័រសឺឡែន មានចាន ចាន់ ពែងដែលបែកបាក់ជាដើម<br>- សំណល់ថ្នាំពេទ្យ* ដែលឈប់ប្រើប្រាស់សំរាប់គ្រួសារ |

| | |
|---|---|
| | - សំណល់ភក់ចេញពីអាងស្តុក (អាងសាបទឹក)<br>- សំណល់ផ្សេងទៀតដែលជាសំណល់មិនបានរៀបរាប់ខាងលើ |
| ២ | **សំណល់នៅតាមទីផ្សារ** |
| | - សំណល់ប្លាស្ទិក<br>- សំណល់លោហៈ*<br>- សំណល់កែវ ដូចជាដប កែវបែក កញ្ចក់<br>- សំណល់ក្រដាស<br>- សំណល់កាតុង<br>- សំណល់ស្បែក ដូចជា ទ្រនាប់ជើង ខ្សែក្រវាត់ កាបូបដៃ ឬកាបូបយួរ និង សំណល់ផ្សេងទៀតដែលផលិតអំពីស្បែក<br>- សំណល់កៅស៊ូ<br>- សំណល់ថ្មពិល*<br>- សំណល់អាគុយ*<br>- សំណល់គ្រឿងអគ្គិសនី*<br>- សំណល់គ្រឿងអេឡិកត្រូនិច*<br>- សំណល់បៃតង<br>- សំណល់ពាំងសីឡែន<br>- សំណល់សាច់ និងឆ្អឹងដែលសល់ពីសកម្មភាពលក់ដូរ<br>- សំណល់ភក់ចេញពីបង្គន់<br>- សំណល់ផ្សេងៗទៀតដែលមិនបានរៀបរាប់ខាងលើ |
| ៣ | **សំណល់តាមភោជណីយដ្ឋាន សណ្ឋាគារ ផ្ទះសំណាក់ កន្លែងលំហែរកាយនិងកន្លែងគោរពបូជា** |
| | - រាល់សំណល់ផ្ទះបាយ ដែលចេញពីសកម្មភាពធាំស្ល<br>- សំណល់ស្រមៀងសំណល់ផ្ទះបាយ<br>- សំណល់បៃតង<br>- សំណល់ប្លាស្ទិក<br>- សំណល់លោហៈ* |

| | |
|---|---|
| | - សំណល់កែវ ដូចជាដបកែវ កែវបែក កញ្ចក់បែកបាក់ជាដើម<br>- សំណល់ក្រដាស ក្រដាសជូតមាត់ ស្រោមចង្កឹះជាដើម<br>- សំណល់ក្រណាត់ ដូចជាកំភលតុ ក្រណាត់ជូតដៃជាដើម<br>- សំណល់កាតុង<br>- សំណល់ជ័រ<br>- សំណល់កៅស៊ូ<br>- សំណល់គ្រឿងអគ្គិសនី*<br>- សំណល់គ្រឿងអេឡិកត្រូនិក*<br>- សំណល់ព័រសីខ្សែន ដូចជាចាន ប៉ាន់ ពែងបែកបាក់ជាដើម<br>- សំណល់ភក់ចេញពីបង្គន់<br>- សំណល់ឈើ ដូចជា តុ ទូ កៅអី ដែលមិនមានលាបថ្នាំ<br>- សំណល់ឈើ ដូចជា តុ ទូ កៅអី មានលាបថ្នាំ*<br>- សំណល់ថ្មពិល*<br>- សំណល់អាគុយ*<br>- សំណល់ផ្សេងទៀតដែលមិនបានរៀបរាប់ខាងលើ និងសំណល់ដែលចេញពីតាមផ្ទះ |
| ៤ | **សំណល់តាមរយៈសេវាសុខភាព ដូចជាតាមមន្ទីរពេទ្យ ពហុព្យាបាល មណ្ឌលសុខភាព** |
| | - សំណល់ស្រដៀងសំណល់ផ្ទះបាយដែលសល់ពីការហូបចុករបស់អ្នកជំងឺ<br>- សំណល់មុតស្រួច* ដូចជាម្ជុល ឡាមជាដើម<br>- សំណល់ឆ្លងរោគ* មើលនៅក្នុង ឧបសម្ព័ន្ធ ១១ នៃគោលការណ៍ណែនាំការគ្រប់សំណល់វេជ្ជសាស្ត្រ<br>- សំណល់ដែលមានផ្ទុកសារធាតុវិទ្យុសកម្ម*<br>- សំណល់ថ្នាំពេទ្យ*<br>- សំណល់មន្ទីរពេទ្យផ្សេងទៀត* មើលក្នុងឧបសម្ព័ន្ធ ១១ ក្នុងគោលការណ៍ណែនាំការគ្រប់គ្រងសំណល់វេជ្ជសាស្ត្រ |

| | |
|---|---|
| ៥ | **សំណល់នៅតាមអាគាររដ្ឋបាលនិងសាលារៀន** |
| | - សំណល់ស្រដៀងសំណល់ផ្ទះបាយ ដែលសល់ពីការហូបចុក<br>- សំណល់ប្លាស្ទិក<br>- សំណល់កៅស៊ូ<br>- សំណល់ក្រដាស<br>- សំណល់កាតុង<br>- សំណល់គ្រឿងអគ្គិសនី*<br>- សំណល់គ្រឿងអេឡិកត្រូនិច*<br>- សំណល់ឈើ ដូចជា តុ ទូ កៅអី ដែលមិនមានលាបថ្នាំ<br>- សំណល់ឈើ ដូចជា តុ ទូ កៅអី មានលាបថ្នាំ*<br>- សំណល់លោហៈ*<br>- សំណល់កែវ<br>- សំណល់ពំរសីខ្សែន<br>- សំណល់ផ្សេងទៀតដែលមិនបានរៀបរាប់ខាងលើ និងសំណល់ដែលចេញពីតាមផ្ទះ |
| ៦ | **សំណល់នៅកន្លែងសេវាកម្មលាងឬជួសជុលរថយន្ត និងជួសជុលគ្រឿងអេឡិកត្រូនិក** |
| | - សំណល់លោហៈ*<br>- សំណល់កៅស៊ូ ដូចជាសំបកកង់យានយន្តចាស់ៗជាដើម<br>- សំណល់ប្លាស្ទិក<br>- សំណល់ថ្នាំបាញ់*<br>- សំណល់អាគុយ*<br>- សំណល់កញ្ចក់ ដូចជាកញ្ចក់យានយន្ត។ល។<br>- សំណល់គ្រឿងអេឡិកត្រូនិក*<br>- សំណល់គ្រឿងអគ្គិសនី*<br>- សំណល់ភក់តាមរយៈសកម្មភាពលាងយានយន្ត<br>- សំណល់ក្រណាត់ដែលប្រើប្រាស់សំរាប់ជូត<br>- សំណល់ក្រណាត់ដែលប្រើប្រាស់សំរាប់ជូតមានប្រឡាក់ប្រេងម៉ាស៊ីន* |

| | |
|---|---|
| | - សំណល់ប្លាស្ទិក |
| | - សំណល់ផ្សេងទៀតដែលមិនបានរៀបរាប់ខាងលើ |
| ៧ | **សំណល់ដែលកើតចេញពីកន្លែងសត្តឃាដ** |
| | - សំណល់លាមកសត្វក្រោយការសំលាប់ |
| | - សំណល់រោមសត្វក្រោយការសំលាប់ |
| | - សំណល់ឆ្អឹង និងសាច់ដែលគេមិនត្រូវការ |
| | - សំណល់ភក់តាមរយៈសកម្មភាពលាងសំអាត |
| | - សំណល់លោហៈ |
| | - សំណល់ផេះ |
| | - សំណល់ផ្សេងទៀតដែលមិនបានរៀបរាប់ខាងលើ |
| ៨ | **សំណល់ដែលកើតពីសកម្មភាពកសិកម្ម** |
| | - សំណល់ឈើ ដូចជាអាចម៍រណា មែកឈើតូចៗជាដើម |
| | - សំណល់លាមកសត្វ (កន្លែងចិញ្ចឹមសត្វ) |
| | - សំណល់សាកសពសត្វ |
| | - សំណល់វេជ្ជសាស្ត្រ ចេញសកម្មភាពព្យាបាលសត្វ |
| | - សំណល់ប្លាស្ទិក |
| | - សំណល់បៃតង |
| | - សំណល់ចំណីសត្វ |
| | - សំណល់ភក់ដែលចេញពីសកម្មភាពដុសលាងសត្វនិងក្រោល |
| | - សំណល់លោហៈ ដែលចេញពីផ្នែកនៃម៉ាស៊ីនកសិកម្ម |
| | - សំណល់សំបកដប ឬកំប៉ុងដែលមានជាប់ជាតិថ្នាំពុលកសិកម្ម |
| | - សំណល់កៅស៊ូ |
| | - សំណល់ផ្សេងទៀតដែលមិនបានរៀបរាប់ខាងលើ |
| ៩ | **សំណល់ឧស្សាហកម្ម និងរ៉ែ** |
| | - សំណល់ក្រណាត់ |
| | - សំណល់ស្បែកនៅតាមរោងចក្រកាត់ដេរស្បែកជើង |

| | |
|---|---|
| | - សំណល់ប្លាស្ទិកសំរាប់វេចខ្ចប់វត្ថុធាតុដើម<br>- សំណល់ក្រដាសនៅក្នុងការិយាល័យ កន្លែងបោះពុម្ព កន្លែងកាត់ពុម្ពខោអាវ<br>- សំណល់កាតុងតាមរយៈការវេចខ្ចប់<br>- សំណល់លោហៈ* គ្រឿងបន្លាស់ម៉ាស៊ីន<br>- សំណល់ភក់តាមរយៈធ្វើប្រព្រឹត្តកម្មទឹកសំអុយ*<br>- សំណល់ធុង ឬកំប៉ុងដែលដាក់សារធាតុគីមី*<br>- សំណល់ថ្នាំជ្រលក់ តាមរយៈសកម្មភាពជ្រលក់ពណ៌ក្រណាត់*<br>- សំណល់ជ័រកាវ*<br>- សំណល់ប្លាស្ទិករឹង<br>- សំណល់គ្រឿងអេឡិកត្រូនិក*<br>- សំណល់គ្រឿងអគ្គិសនី*<br>- សំណល់កែវ ដេរតាមរោងផលិតភេសជ្ជៈ ឬសិប្បកម្មផលិតទឹកត្រី ទឹកស៊ីអ៊ីវ<br>- សំណល់ធាយស្រា<br>- សំណល់ស្រដៀងសំណល់ផ្ទះបាយ<br>- សំណល់ផ្សេងៗទៀតដែលមិនបានរៀបរាប់ខាងលើ |
| ១០ | **សំណល់សំណង់** |
| | - សំណល់ប្លាស្ទិក<br>- សំណល់ឈើ<br>- សំណល់ឈើមានលាបថ្នាំ*<br>- សំណល់កំទេចថ្មគ្រប់ប្រភេទ<br>- សំណល់ដែលជីកចោល<br>- សំណល់កាតុង ចេញពីការវេចខ្ចប់<br>- សំណល់លោហៈ*<br>- សំណល់ជ័រស៊ីឡែន<br>- សំណល់ថ្នាំលាប*<br>- សំណល់ស៊ីម៉ង់ត៍*<br>- សំណល់កំបោរ* |

| | |
|---|---|
| | - សំណល់ជ័រកៅស៊ូ*<br>- សំណល់កែវ<br>- សំណល់គ្រឿងអគ្គិសនី*<br>- សំណល់ប្លាស្ទិករឹង<br>- សំណល់ផ្សេងទៀតដែលមិនបានរៀបរាប់ខាងលើ |
| **១១** | **សំណល់ចេញពីមន្ទីរពិសោធន៍** |
| | - សំណល់កែវ*<br>- សំណល់សារធាតុគីមី*<br>- សំណល់សំណាក*<br>- សំណល់លោហៈ*<br>- សំណល់គ្រឿងអគ្គិសនី*<br>- សំណល់គ្រឿងអេឡិកត្រូនិក*<br>- សំណល់កៅស៊ូ*<br>- សំណល់ខោអាវ ក្រណាត់*<br>- សំណល់ដែលមានសារធាតុវិទ្យុសកម្ម*<br>- សំណល់ផ្សេងទៀតដែលមិនបានរៀបរាប់ខាងលើ |
| **១២** | **សំណល់នៅតាមថ្នល់** |
| | - សំណល់ប្លាស្ទិក<br>- សំណល់ក្រដាស<br>- សំណល់កាតុង<br>- សំណល់លោហៈ*<br>- សំណល់ឈើ<br>- សំណល់បៃតង<br>- សំណល់ដី និងថ្ម<br>- សំណល់កែវ<br>- សំណល់សាកសពសត្វ<br>- សំណល់លាមកសត្វ |

| | |
|---|---|
| | - សំណល់ផ្សេងទៀតដែលមិនបានរៀបរាប់ខាងលើ |
| ១៣ | **សំណល់តាមស្ទូនច្បារ** |
| | - សំណល់ប្លាស្ទិក<br>- សំណល់ក្រដាស<br>- សំណល់កាតុង<br>- សំណល់លោហៈ<br>- សំណល់ឈើ<br>- សំណល់បៃតង<br>- សំណល់ដី ថ្ម<br>- សំណល់កែវ<br>- សំណល់សាកសពសត្វ<br>- សំណល់លាមកសត្វ<br>- សំណល់ផ្សេងទៀតដែលមិនបានរៀបរាប់ខាងលើ |

__សំគាល់__ សំណល់ណាដែលមានសញ្ញាផ្កាយ (*) ជាសំណល់ប្រកបដោយគ្រោះថ្នាក់

**ឧបសម្ព័ន្ធ ២: មធ្យោបាយចាក់ចោល**

- នៅលើទីលានបទដ្ឋានសាមញ្ញ
- នៅលើទីលានអនាម័យ
- នៅលើទីលានសំណល់ប្រកបដោយគ្រោះថ្នាក់
- ដុតចោលនៅក្នុងឡសំរាប់តែសំណល់វេជ្ជសាស្ត្រ

**ឧបសម្ព័ន្ធ ៣: មធ្យោបាយប្រព្រឹត្តកម្ម**

- ស្តារឡើងវិញ (ឧទាហរណ៍ ការធ្វើជីកំប៉ុស្ដិ៍)
- ប្រើប្រាស់ឡើងវិញ
- កែច្នៃឡើងវិញ

## ឧបសម្ព័ន្ធ ៤: ទំរង់បែបបទនៃផែនការគ្រប់គ្រងសំណល់រឹង

### ១. ទំព័រទី១ (ទំព័រគំរបខាងក្រៅ)

- គំរោងផែនការគ្រប់គ្រងសំណល់រឹង
- ការបរិច្ឆេទ
- ឈ្មោះអ្នកដែលទទួលខុសត្រូវក្នុងការរៀបចំផែនការគ្រប់គ្រងសំណល់រឹង

### ២. ទំរង់បែបបទទទួលខុសត្រូវ

- ឈ្មោះស្ថាប័ន
- ឈ្មោះនិងតួនាទីអ្នកធ្វើផែនការ
- អាស័យដ្ឋាន

### ៣. ទំរង់ផែនការ.

| ប្រភេទសំណល់ | ប្រភព | លំហូរ | បរិមាណគិតជាតោន | | |
|---|---|---|---|---|---|
| | | | 2005 | 2006 | --- |
| ១ សំណល់ផ្ទះបាយ | តាមផ្ទះ | ទីលាន | ១០០ | ៧៥ | - |
| ២ ក្រដាស | ការិយាល័យ | កែច្នៃ | ៣៥ | ២៥ | - |
| ៣ វេជ្ជសាស្ត្រ | មន្ទីរពេទ្យ | ដុត | ៥ | ១២ | - |
| ៤ | - | - | - | - | - |
| ៥ | - | - | - | - | - |
| | - | - | - | - | - |
| | - | - | - | - | - |

### ៤. ទំរង់បែបបទការទទួលស្គាល់

- ព័ត៌មាន ស្តីអំពី ការចាក់ចោលសំណល់
- ទិន្នន័យសំណល់ដែលចាក់ចោល
- ទិន្នន័យដំណើរការចាក់ចោលសំណល់

៥. ទំរង់បែបបទពេលណាមានទីលានខ្លួនឯង

- ដំណើរការទីលាន
- បកស្រាយពីមូលហេតុនៃការបង្កើតទីលានខ្លួនឯង

៦. ទំរង់បែបបទពេលណាមានទីលានខ្លួនឯង

- ត្រូវមានព័ត៌មានច្បាស់លាស់ ស្តីអំពី មធ្យោបាយចាក់ចោល។

ឧបសម្ព័ន្ធ ៥ ប្រភេទសំណល់រឹងដែលត្រូវចាក់ចោលនៅទីលានប្រភេទផ្សេងៗគ្នា

| លរ | ប្រភព និងប្រភេទសំណល់ | ខបស | ខអម | ខសគថ |
|---|---|---|---|---|
| ១ | **សំណល់តាមផ្ទះ** | | | |
| | - សំណល់ផ្ទះបាយដែលកើតឡើងតាមរយៈសកម្មភាពដាំស្ល | x | x | |
| | - សំណល់ប្លាស្ទិកដែលក្រោយពេលគេឈប់ប្រើប្រាស់សំរាប់វេចខ្ចប់ | x | x | |
| | - សំណល់ក្រណាត់ដែលកើតឡើងតាមរយៈសមកម្មភាពកាត់ដេរបន្តិចបន្តួច ឬកន្ទបសំរាប់ជូតចានឆ្នាំង ឬជូតផ្ទះជាដើម | x | x | |
| | - សំណល់សំលៀកបំពាក់ចាស់ៗដែលគេឈប់ប្រើប្រាស់ | x | x | |
| | - សំណល់លោហៈ* | | | x |
| | - សំណល់កែវ មានដប កែវបែក កញ្ចក់ ជាដើម | x | x | |
| | - សំណល់ក្រដាស ដែលកើតពីការវេចខ្ចប់ កាសែតអាន ។ល។ | x | x | |
| | - សំណល់ក្រដាសកាតុង | x | x | |
| | - សំណល់ឈើមិនមានលាបថ្នាំ ដូចជាគ្រឿងសង្ហារឹមដែលបាក់បែកដែលគេឈប់ប្រើ | x | x | |
| | - សំណល់ឈើមានលាបថ្នាំ* | | | x |
| | - សំណល់ស្បែក ដូចជា ទ្រនាប់ជើង ខ្សែក្រវាត់ កាបូបដៃ ឬកាបូបយួរដែលឈប់ប្រើប្រាស់ ។ល។ | x | x | |
| | - សំណល់កៅស៊ូ ដូចជាកៅស៊ូកង់ កៅស៊ូកង់យានជំនិះ និងសំណល់ផ្សេងទៀតដែលធ្វើអំពីកៅស៊ូ ។ល។ | x | x | |
| | - សំណល់ថ្មពិល* | | | x |
| | - សំណល់អាគុយ* | | | x |
| | - សំណល់គ្រឿងអគ្គិសនី* | | | x |
| | - សំណល់គ្រឿងអេឡិកត្រូនិក* | | | x |

| | | | | |
|---|---|---|---|---|
| | - សំណល់បៃតង មានដូចជាបន្លែ ផ្លែឈើ ស្មៅ មែកឈើ ស្លឹកឈើ។ល។ | x | x | |
| | - សំណល់ព័រសីខ្សែន មានចាន ប៉ាន់ ពែងដែលបែកបាក់ជាដើម | x | x | |
| | - សំណល់ថ្នាំពេទ្យ* ដែលឈប់ប្រើប្រាស់សំរាប់គ្រួសារ | x | x | |
| | - សំណល់ភក់ចេញពីអាងស្តុក (អាងសាបទិក) | x | x | x |
| | - សំណល់ផ្សេងទៀតដែលជាសំណល់មិនបានរៀបរាប់ខាងលើ | x | x | x |
| ២ | **សំណល់នៅតាមទីផ្សារ** | | | |
| | - សំណល់ប្លាស្ទិក | x | x | |
| | - សំណល់លោហៈ* | | | x |
| | - សំណល់កែវ ដូចជាដប កែវបែក កញ្ចក់ | x | | |
| | - សំណល់ក្រដាស | x | | |
| | - សំណល់កាតុង | x | | |
| | - សំណល់ស្បែក ដូចជា ទ្រនាប់ជើង ខ្សែក្រវាត់ កាបូបដៃ ឬកាបូបយួរ និងសំណល់ផ្សេងទៀតដែលផលិតអំពីស្បែក | x | | |
| | - សំណល់កៅស៊ូ | x | | |
| | - សំណល់ថ្មពិល* | | | x |
| | - សំណល់អាគុយ* | | | x |
| | - សំណល់គ្រឿងអគ្គិសនី* | | | x |
| | - សំណល់គ្រឿងអេឡិកត្រូនិក* | | | x |
| | - សំណល់បៃតង | x | x | |
| | - សំណល់ព័រសីខ្សែន | x | x | |
| | - សំណល់សាច់និងឆ្អឹងដែលសល់ពីសកម្មភាពលក់ដូរ | x | x | |
| | - សំណល់ភក់ចេញពីបង្គន់ | x | x | |

| | | | | |
|---|---|---|---|---|
| | - សំណល់ផ្សេងៗទៀតដែលមិនបានរៀបរាប់ខាងលើ | x | x | x |
| ៣ | **សំណល់តាមរោងចក្រ សណ្ឋាគារ ផ្ទះសំណាក់ កន្លែងលំហែកាយ និងកន្លែងគោរពបូជា** | | | |
| | - រាល់សំណល់ផ្ទះបាយដែលចេញពីសកម្មភាពដាំស្ល | x | x | |
| | - សំណល់ស្រដៀងសំណល់ផ្ទះបាយ | x | x | |
| | - សំណល់បៃតង | x | x | |
| | - សំណល់ប្លាស្ទិក | x | x | |
| | - សំណល់លោហៈ* | | | x |
| | - សំណល់កែវ ដូចជាដប កែវបែក កញ្ចក់ បែកបាក់ជាដើម | x | x | |
| | - សំណល់ក្រដាស ក្រដាសជូតមាត់ ស្រោមចង្កឹះជាដើម | x | x | |
| | - សំណល់ក្រណាត់ ដូចជាកំរាលតុ ក្រណាត់ជូតដៃជាដើម | x | x | |
| | - សំណល់កាតុង | x | x | |
| | - សំណល់ជ័រ | x | x | |
| | - សំណល់កៅស៊ូ | x | x | |
| | - សំណល់គ្រឿងអគ្គិសនី* | | | x |
| | - សំណល់គ្រឿងអេឡិកត្រូនិក* | | | x |
| | - សំណល់ព័រសីឡែន ដូចជាចាន ចាន់ ពែងបែកបាក់ជាដើម | x | x | |
| | - សំណល់ភក់ចេញពីបង្គន់ | x | x | |
| | - សំណល់ឈើ ដូចជា តុ ទូ កៅអី ដែលមិនមានលាបថ្នាំ | x | x | |
| | - សំណល់ឈើ ដូចជា តុ ទូ កៅអី មានលាបថ្នាំ* | | | x |
| | - សំណល់ថ្មពិល* | | | x |
| | - សំណល់អាគុយ* | | | x |
| | - សំណល់ផ្សេងទៀតដែលមិនបានរៀបរាប់ខាងលើនិង សំណល់ដែលចេញពីតាមផ្ទះ | x | x | x |

| | | | | |
|---|---|---|---|---|
| ៤ | **សំណល់តាមរយៈសេវាសុខភាព ដូចជាតាមមន្ទីរពេទ្យ ពហុព្យាបាល មណ្ឌលសុខភាព** | | | |
| | - សំណល់ស្រដៀងសំណល់ផ្ទះបាយដែលសល់ពីការហូបចុករបស់អ្នកជំងឺ | x | x | |
| | - សំណល់មុតស្រួច* ដូចជាម្ជុល ឡាមជាដើម | | | x |
| | - សំណល់ឆ្លងរោគ* មើលនៅក្នុងឧបសម្ព័ន្ធ ១១ | | | x |
| | - សំណល់ដែលមានបន្ទុកសារធាតុវិទ្យុសកម្ម* | | | x |
| | - សំណល់ថ្នាំពេទ្យ* | | | x |
| | - សំណល់មន្ទីរពេទ្យផ្សេងទៀត* មើលក្នុងឧបសម្ព័ន្ធ ១១ | | | x |
| ៥ | **សំណល់នៅតាមអាគាររដ្ឋបាល និងសាលារៀន** | | | |
| | - សំណល់ស្រដៀងសំណល់ផ្ទះបាយ ដែលសល់ពីការហូបចុក | x | x | |
| | - សំណល់ប្លាស្ទិក | x | x | |
| | - សំណល់កៅស៊ូ | x | x | |
| | - សំណល់ក្រដាស | x | | |
| | - សំណល់កាតុង | x | x | |
| | - សំណល់គ្រឿងអគ្គិសនី* | | | x |
| | - សំណល់គ្រឿងអេឡិកត្រូនិក* | | | x |
| | - សំណល់ឈើ ដូចជា តុ ទូ កៅអី ដែលមិនមានលាបថ្នាំ | x | x | |
| | - សំណល់ឈើ ដូចជា តុ ទូ កៅអី មានលាបថ្នាំ* | | | x |
| | - សំណល់លោហៈ* | | | x |
| | - សំណល់កែវ | x | x | |
| | - សំណល់ព័រសឺឡែន | x | x | |
| | - សំណល់ផ្សេងទៀតដែលមិនបានរៀបរាប់ខាងលើនិងសំណល់ដែលចេញពីតាមផ្ទះ | x | x | x |

| | | | | |
|---|---|---|---|---|
| ៦ | **សំណល់នៅកន្លែងសេវាកម្មលាង ឬជួសជុលរថយន្ត និងជួសជុលគ្រឿងអេឡិកត្រូនិក** | | | |
| | - សំណល់លោហៈ* | | | x |
| | - សំណល់កៅស៊ូ ដូចជាសំបកកង់យានយន្តចាស់ៗជាដើម | x | x | |
| | - សំណល់ប្លាស្ទិក | x | x | |
| | - សំណល់ថ្នាំបាញ់* | | | x |
| | - សំណល់អាគុយ* | | | x |
| | - សំណល់កញ្ចក់ ដូចជាកញ្ចក់យានយន្ត។ល។ | x | x | |
| | - សំណល់គ្រឿងអេឡិកត្រូនិក* | | | x |
| | - សំណល់គ្រឿងអគ្គិសនី* | | | x |
| | - សំណល់ភក់តាមរយៈសកម្មភាពលាងយានយន្ត | x | x | |
| | - សំណល់ក្រណាត់ដែលប្រើប្រាស់សំរាប់ជូត | x | x | |
| | - សំណល់ក្រណាត់ដែលប្រើប្រាស់សំរាប់ជូតមានប្រឡាក់ប្រេងម៉ាស៊ីន* | | | x |
| | - សំណល់ប្លាស្ទិក | x | x | |
| | - សំណល់ផ្សេងទៀតដែលមិនបានរៀបរាប់ខាងលើ | x | x | x |
| ៧ | **សំណល់ដែលកើតចេញពីកន្លែងសត្តឃាដ** | | | |
| | - សំណល់លាមកសត្វក្រោយការសំលាប់ | x | x | |
| | - សំណល់រោមសត្វក្រោយការសំលាប់ | x | x | |
| | - សំណល់ឆ្អឹងនិងសាច់ដែលគេមិនត្រូវការ | x | x | |
| | - សំណល់ភក់តាមរយៈសកម្មភាពលាងសំអាត | x | x | |
| | - សំណល់លោហៈ* | | | x |
| | - សំណល់ជ័រ | x | x | |
| | - សំណល់ផ្សេងទៀតដែលមិនបានរៀបរាប់ខាងលើ | x | x | x |

| | | | | |
|---|---|---|---|---|
| ៨ | **សំណល់ដែលកើតពីសកម្មភាពកសិកម្ម** | | | |
| | - សំណល់ឈើ ដូចជាអាចម៍រណា មែកឈើតូចៗជាដើម | x | x | |
| | - សំណល់លាមកសត្វ (កន្លែងចិញ្ចឹមសត្វ) | x | x | |
| | - សំណល់សាកសពសត្វ | x | x | |
| | - សំណល់វេជ្ជសាស្ត្រ ចេញសកម្មភាពព្យាបាលសត្វ | | | x |
| | - សំណល់ប្លាស្ទិក | x | x | |
| | - សំណល់បៃតង | x | x | |
| | - សំណល់ចំណីសត្វ | x | x | |
| | - សំណល់ភក់ដែលចេញពីសកម្មភាពផុសលាងសត្វនិងក្រោល | x | x | |
| | - សំណល់លោហៈ ដែលចេញពីផ្នែកនៃម៉ាស៊ីនកសិកម្ម | x | x | |
| | - សំណល់សំបកដប ឬកំប៉ុងដែលមានជាប់ជាតិថ្នាំពុលកសិកម្ម | | | x |
| | - សំណល់កៅស៊ូ | x | x | |
| | - សំណល់ផ្សេងទៀតដែលមិនបានរៀបរាប់ខាងលើ | x | x | x |
| ៩ | **សំណល់ឧស្សាហកម្ម និងរ៉ែ** | | | |
| | - សំណល់ក្រណាត់ | x | x | |
| | - សំណល់ស្បែកនៅតាមរោងចក្រកាត់ដេរស្បែកជើង | x | x | |
| | - សំណល់ប្លាស្ទិកសំរាប់វេចខ្ចប់វត្ថុធាតុដើម | x | x | |
| | - សំណល់ក្រដាសនៅក្នុងការិយាល័យ កន្លែងបោះពុម្ព កន្លែងកាត់ពុម្ពខោអាវ | x | x | |
| | - សំណល់កាតុងតាមរយៈការវេចខ្ចប់ | x | x | |
| | - សំណល់លោហៈ គ្រឿងបន្លាស់ម៉ាស៊ីន | x | x | |
| | - សំណល់ភក់តាមរយៈធ្វើប្រព្រឹត្តកម្មទឹកសំអុយ | | | x |
| | - សំណល់ធុង ឬកំប៉ុងដែលដាក់សារធាតុគីមី | | | x |

| | | | | |
|---|---|---|---|---|
| | - សំណល់ថ្នាំជ្រលក់ តាមរយៈសកម្មភាពជ្រលក់ ពណ៌ក្រណាត់* | | | x |
| | - សំណល់ជ័រកាវ* | | | x |
| | - សំណល់ប្លាស្ទិករឹង | x | x | |
| | - សំណល់គ្រឿងអេឡិកត្រូនិក* | | | x |
| | - សំណល់គ្រឿងអគ្គិសនី* | | | x |
| | - សំណល់កែវ នៅតាមរោងផលិតភេសជ្ជៈ ឬសិប្បកម្មផលិតទឹកត្រី ទឹកស៊ីអ៊ីវ | x | x | |
| | - សំណល់បាយស្រា | x | x | |
| | - សំណល់ស្រដៀងសំណល់ផ្ទះបាយ | x | x | |
| | - សំណល់ផ្សេងៗទៀតដែលមិនបានរៀបរាប់ខាងលើ | x | x | x |
| ១០ | **សំណល់សំណង់** | | | |
| | - សំណល់ប្លាស្ទិក | x | x | |
| | - សំណល់ឈើ | x | x | |
| | - សំណល់ឈើមានលាបថ្នាំ* | | | x |
| | - សំណល់កំទេចថ្មគ្រប់ប្រភេទ | x | x | |
| | - សំណល់ដែលជីកចោល | x | x | |
| | - សំណល់កាតុង ចេញពីការវេចខ្ចប់ | x | x | |
| | - សំណល់លោហៈ* | | | x |
| | - សំណល់ព័រសឺឡែន | x | x | |
| | - សំណល់ថ្នាំលាប* | | | x |
| | - សំណល់ស៊ីម៉ង់* | | | x |
| | - សំណល់កំបោរ* | | | x |
| | - សំណល់ជ័រកាវ* | | | x |

| | | | | |
|---|---|---|---|---|
| | - សំណល់កែវ | x | x | |
| | - សំណល់គ្រឿងអគ្គិសនី* | | | x |
| | - សំណល់ប្លាស្ទិករឹង | x | x | x |
| | - សំណល់ផ្សេងទៀតដែលមិនបានរៀបរាប់ខាងលើ | x | x | x |
| ១១ | **សំណល់ចេញពីមន្ទីរពិសោធន៍** | | | |
| | - សំណល់កែវ* | | | x |
| | - សំណល់សារធាតុគីមី* | | | x |
| | - សំណល់សំណាក* | | | x |
| | - សំណល់លោហៈ* | | | x |
| | - សំណល់គ្រឿងអគ្គិសនី* | | | x |
| | - សំណល់គ្រឿងអេឡិកត្រូនិក* | | | x |
| | - សំណល់កៅស៊ូ* | | | x |
| | - សំណល់ខោអាវ ក្រណាត់* | | | x |
| | - សំណល់ដែលមានសារធាតុវិទ្យុសកម្ម* | | | x |
| | - សំណល់ផ្សេងទៀតដែលមិនបានរៀបរាប់ខាងលើ* | | | x |
| ១២ | **សំណល់នៅតាមថ្នល់** | | | |
| | - សំណល់ប្លាស្ទិក | x | x | |
| | - សំណល់ក្រដាស | x | x | |
| | - សំណល់កាតុង | x | x | |
| | - សំណល់លោហៈ* | | | x |
| | - សំណល់ឈើ | x | x | |
| | - សំណល់បែតុង | x | x | |
| | - សំណល់ដី ថ្ម | x | x | |
| | - សំណល់កែវ | x | x | |

| | | | | |
|---|---|---|---|---|
| | - សំណល់សាកសពសត្វ | x | x | |
| | - សំណល់លាមកសត្វ | x | x | |
| | - សំណល់ផ្សេងទៀតដែលមិនបានរៀបរាប់ខាងលើ | x | x | x |
| ១៣ | **សំណល់តាមសួនច្បារ** | | | |
| | - សំណល់ប្លាស្ទិក | x | x | |
| | - សំណល់ក្រដាស | x | x | |
| | - សំណល់កាតុង | x | x | |
| | - សំណល់លោហៈ | | | x |
| | - សំណល់ឈើ | x | x | |
| | - សំណល់បៃតង | x | x | |
| | - សំណល់ដី ថ្ម | x | x | |
| | - សំណល់កែវ | x | x | |
| | - សំណល់សាកសពសត្វ | x | x | |
| | - សំណល់លាមកសត្វ | x | x | |
| | - សំណល់ផ្សេងទៀតដែលមិនបានរៀបរាប់ខាងលើ | x | x | x |

## ឧបសម្ព័ន្ធ ៦ កំណត់សំគាល់បច្ចេកទេស

ក) អនុសាសន៍ តំរូវការ និងភារកិច្ច ក្នុងការចាត់ចែងការងារ ការគ្រប់គ្រងបុគ្គលិក ព័ត៌មាន ការចងក្រងឯកសារ និងការប្រតិបត្តិទីលាន

| អនុសាសន៍ តំរូវការ ឬភារកិច្ច | ប្រភេទទីលាន | | |
|---|---|---|---|
| | **ទីលានបចង្ហានសាមញ្ញ** | **ទីលានអនាម័យ** | **ទីលានសំណល់ប្រកបដោយគ្រោះថ្នាក់** |
| **១. ព័ត៌មាន និងការចងក្រងឯកសារ** Information and Documentation | | | |
| **១.១ បទបញ្ជាការងារ** Working Regulatons | | | |
| | អ្នកគ្រប់គ្រងទីលានមានបទបញ្ជាការងារមួយ ត្រូវរៀបចំឱ្យហើយមុនចាប់ផ្តើមអនុវត្តការងារ។ បទបញ្ជានេះអាចអនុញ្ញាតអោយធ្វើការកែលំអជានិច្ចដើម្បីអោយមានភាពកាន់តែប្រសើរឡើង។<br>នៅក្នុងបទបញ្ជាការងារត្រូវ÷<br>ក_ បរិយាយអោយបានច្បាស់ពីសុវត្ថិភាពការងារ និងអំពីវិន័យការងារ ហើយត្រូវបញ្ជូនទៅឱ្យអាជ្ញាធរទទួលខុសត្រូវ។<br>ខ_ មានចែងពីនិតិវិធីប្រតិបត្តិការ បច្ចេកទេសគ្រប់គ្រងសំណល់ ហើយត្រូវសរសេរឱ្យងាយយល់ និងងាយអនុវត្ត។<br>គ_ បទបញ្ជាការងារត្រូវដាក់នៅកន្លែងសំខាន់ៗ ពិសេសនៅកន្លែងច្រកចូល (entrance area)។ | | |

| | |
|---|---|
| | ឃ_ កំណត់ពីវិធានការគ្រប់គ្រងសំណល់គ្រប់ប្រភេទឱ្យបានច្បាស់លាស់។ |
| **១.២ សេចក្តីណែនាំអំពីការប្រតិបត្តិការងារ** Operation Manual | |
| | អ្នកគ្រប់គ្រងទីលាន ត្រូវតែរៀបចំសេចក្តីណែនាំអំពីការប្រតិបត្តិការងារមុនពេលចាប់ផ្តើមអនុវត្ត។ សេចក្តីណែនាំនេះអាចអនុញ្ញាតឱ្យធ្វើការកែលំអជានិច្ច ដើម្បីឱ្យមានភាពកាន់តែប្រសើរឡើង។<br>នៅក្នុងសេចក្តីណែនាំនោះត្រូវសរសេរឱ្យបានច្បាស់នូវ÷<br>ក_ វិធានការលើការអនុវត្តន៍ ការថែទាំ ក៏ដូចជាភារកិច្ចការពារ។ រាល់វិធានការទាំងអស់នោះត្រូវផ្សាភ្ជាប់ជាមួយនឹងផែនការ និងកាលបរិច្ឆេទក្នុងការអនុវត្តន៍ដោយប្រុងប្រយ័ត្ន។<br>ខ_ ភារកិច្ចនៃបុគ្គលិក ព្រមទាំងការទទួលខុសត្រូវដូចមានចែងក្នុងចំណុច ៨.១ នៃគោលការណ៍ណែនាំស្តីពី ការគ្រប់គ្រង និងការសាងសង់ទីលាន ហើយក៏ត្រូវធ្វើការដឹកនាំការងារ និងធ្វើការអង្កេត ពិនិត្យ វិធានការថែរក្សា ក៏ដូចជាព័ត៌មាន និងការចងក្រងឯកសារ។ |
| **១.៣ កំណត់ត្រាការងារ** Operating Journal | |
| | អ្នកប្រតិបត្តិទីលានត្រូវរៀបចំសៀវភៅកត់ត្រាប្រចាំថ្ងៃមុនពេលចាប់ផ្តើមអនុវត្ត ដើម្បីពិនិត្យទៅលើការងារប្រតិបត្តិឱ្យបានត្រឹមត្រូវ គ្រប់គ្រងទិន្នន័យ និងព័ត៌មានដែលទាក់ទងទៅនឹងការងារទាំងអស់នៅលើទីលាន ដូចជា÷<br>ក_ ទិន្នន័យសំណល់ដែលបានដឹកចូល ដូចជាបរិមាណគិតជាឯកតាទំងន់ និងជាមានក្នុងករណីដែលអាចធ្វើទៅបាន ប្រភេទ និងលំហូររបស់វា។ |

| | |
|---|---|
| | ខ- លទ្ធផលការងារតាមដាន និងការត្រួតពិនិត្យសំណល់ចូលទីលាន។<br>គ- ករណីមិនប្រក្រតីដែលកើតមានឡើង ដោយមានការកត់ត្រាពីមូលហេតុ ព្រមទាំងដំណោះស្រាយ។<br>ឃ- ម៉ោងការងារ ម៉ោងសំរាក។<br>ង- ទំហំនិងវិធានការថែរក្សា និងការជួលជុល ។ល។<br>រាល់ការត្រួតពិនិត្យណាមួយដែលជាការទាមទារពីអាជ្ញាធរទទួលខុសត្រូវ ក៏ដូចជាលទ្ធផលត្រួតពិនិត្យ ត្រូវតែកត់ចូលទៅក្នុងសៀវភៅកត់ត្រាផងដែរ។<br>សៀវភៅកត់ត្រាត្រូវ÷<br>ក- មានការត្រួតពិនិត្យយ៉ាងទៀងទាត់ពីក្រុមត្រួតពិនិត្យរបស់ទីលាន ហើយត្រូវការពារមិនឱ្យបាត់ និងមិនអោយអ្នកណាដែលគ្មានភារកិច្ចកាន់កាប់ឡើយ។<br>ខ- ចំហជារៀងរាល់ពេលសំរាប់ការត្រួតពិនិត្យ និងត្រូវសរសេរអក្សរឱ្យបានច្បាស់។<br>គ- រក្សាទុកមួយរយៈ រហូតដល់ក្រោយពេលពិនិត្យឃើញថាមិនមានផលវិបាកអ្វី ក្រោយពេលបិទទីលានមួយកន្លែងៗ ដោយមានការយល់ព្រមពីអាជ្ញាធរទទួលខុសត្រូវ។<br>ក្នុងករណីយមានសំណើ សៀវភៅកត់ត្រាត្រូវបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ច។ |
| **១.៤ កាតព្វកិច្ចក្នុងការផ្តល់ព័ត៌មានទៅអាជ្ញាធរ** Obligations to give information to the authorities | |
| | អ្នកទទួលខុសត្រូវដំណើរការទីលាន មានកាតព្វកិច្ចធ្វើរបាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំដោយមានទិន្ន័យជាក់លាក់ ស្តីអំពី ដំណើរការគ្រប់គ្រងទីលាន បញ្ជូនទៅអាជ្ញាធរទទួលខុសត្រូវ។ ប្រសិនបើមានហេតុការណ៍មិនប្រក្រតីកើតឡើង ដែលនាំឱ្យមានការរាំងស្ទះដល់ដំណើរការគ្រប់គ្រងទីលាន ត្រូវធ្វើរបាយការណ៍ជាបន្ទាន់ទៅ |

| | |
|---|---|
| | អាជ្ញាធរទទួលខុសត្រូវ។ |
| **២. ប្រតិបត្តិការទីលាន** Operation | |
| **២.១ ត្រួតពិនិត្យដោយធ្វើការវិភាគ** Control Analysis | |
| | ការត្រួតពិនិត្យដោយធ្វើការវិភាគធ្វើនៅពេលសំណល់មកដល់ក្នុងនោះត្រូវ ÷<br>ក_ ស្រាវជ្រាវប្រភេទសំណល់<br>ខ_ ឆែកសំណល់ដឹកចូលដោយផ្ទាល់ភ្នែក បន្ទាប់មកទៀតត្រូវមានការត្រួតពិនិត្យដោយមានធ្វើការវិភាគដោយបុគ្គលិកទទួលបន្ទុក។<br>គ_ ធ្វើអធិការកិច្ចផ្ទាល់ភ្នែកសំណល់ដឹកចូលក្នុងនិកាសសមស្រប ដោយមិនឱ្យអ្នកដឹកសំណល់ដឹងជាមុន។<br>ឃ_បុគ្គលិកនៅកន្លែងចាក់សំណល់ (Landfilling Area) ត្រូវមានការប្រុងប្រយ័ត្នជានិច្ចទៅលើករណីយមិនប្រក្រតីណាមួយ ដូចជាការឃើញមានពណ៌ ឬក្លិនចំឡែកកើតឡើង។ ក្នុងករណីនេះ ត្រូវមានការពិនិត្យវិភាគឡើងវិញ ដោយមានការប្រៀបធៀបលើឯកសារដែលមាននិងទៅលើប៉ារ៉ាម៉ែត្រសំណល់ និងចរិកលក្ខណៈរបស់សំណល់។<br>រាល់លទ្ធផលនៃការពិនិត្យវិភាគលើចំណុច ក ដល់ ឃ ខាងលើត្រូវមានការកត់ត្រានៅក្នុងសៀវភៅកំណត់ត្រាឱ្យបានត្រឹមត្រូវ។ |
| **២.២ កម្មវិធីប្រតិបត្តិទីលាន** Operation plan | |
| | នៅក្នុងកម្មវិធីប្រតិបត្តិទីលានមានបង្ហាញនូវគោលការណ៍សំខាន់ៗក្នុងការប្រតិបត្តិទីលាន ជាពិសេសនៅលើ |

| | |
|---|---|
| | ទីតាំងគំនរសំណល់ (lanfilling body) ការរៀបចំប្រព័ន្ធប្រមូល ឬបញ្ចេញចោលឧស្ម័នទីលាន និងទឹកសំអុយទីលាន ព្រមទាំងទឹកសំអុយផងទៀត។<br><br>ប្រសិនបើមានការចាំបាច់ ត្រូវធ្វើការបែងចែកទីលានចាក់សំណល់ (lanfilling area ) ជាកន្លែងចាក់តូចៗបន្តទៅទៀត ហើយការបែងចែកនោះត្រូវធ្វើឡើងផ្អែកទៅលើព័ត៌មានដូចខាងក្រោម ÷<br>- ប្រភេទសំណល់<br>- ទំហំកន្លែងចាក់សំណល់<br>- របៀបចាក់សំណល់។ |
| **២.៣ ផែនការចាក់សំណល់** Landfilling Plan | |
| | ក្នុងករណីទីលានចាក់សំណល់ (lanfilling area ) មានការបែងចែកជាកន្លែងចាក់សំណល់តូចៗ តទៅទៀត ទីលានចាក់សំណល់ត្រូវបែងចែកជាក្រឡាចក្រត្រង់ ជាឧទាហរណ៍ត្រូវមានទំហំមិនឱ្យលើស ២៥០០ម៉ែត្រការ៉េ។ នៅរាល់ទីចក្រត្រង់និមួយៗ ត្រូវរៀបចំផែនការបែងចែកវាដោយយោងទៅតាមទិន្ន័យដូចខាងក្រោមនេះ÷<br>ក- ប្រភេទ និងបរិមាណសំណល់<br>ខ- ទីតាំងចាក់សំណល់<br>គ- របៀបចាក់សំណល់<br>• កំរាស់ស្រទាប់សំណល់<br>• ឧបករណ៍បង្ហាប់សំណល់ |

| | | |
|---|---|---|
| | ឃ_ រយៈពេលចាក់សំណល់<br>ង_ ភាពលំអៀង ឬឱបសគ្គ និងផែនការ។ | |
| **២.៤ កាលវិភាគធ្វើបញ្ជីសារពើភ័ណ្ឌ** Inventory Schedule | | |
| | ផែនការសារពើភ័ណ្ឌត្រូវធ្វើយ៉ាងយូរបំផុត ៦ខែក្រោយពេលកន្លែងចាក់សំណល់មួយៗត្រូវបានចាក់ពេញ ដោយត្រូវបរិយាយពីស្រទាប់សំណល់ផងដែរ។ | |
| **២.៥ ទំរង់គំនរសំណល់នៃទីលាន** Structure of Landfill Body | | |
| | ការទុកដាក់សំណល់ត្រូវ ÷<br>ក_ ធ្វើយ៉ាងណាឱ្យទីលានប្រើប្រាស់បានយូរ និងប្រើអស់លទ្ធភាព។<br>ខ_ ធ្វើយ៉ាងណាឱ្យគំនរសំណល់មានលំនឹង ជើងទេត្រូវមានទំហំអតិបរមា ១/៣ នៃជើងក្រោម។<br>គ_ មិនឱ្យមានសាយភាយចេញ ដូចជាទឹកសំអុយ ឬឧស្ម័ន។<br>ឃ_ ត្រូវរៀបចំគំនរសំណល់មិនឱ្យមានប្រតិកម្មកើតឡើងរវាងសំណល់និងសំណល់ ឬសំណល់ជាមួយទឹកសំអុយ។ | |
| | | ក្រៅពីករណីពី ក ដល់ ឃ ខាងលើ សំរាប់ទីលានអនាម័យ និងទីលានសំណល់ប្រកបដោយគ្រោះថ្នាក់ ទំរង់គំនរសំណល់ទីលានត្រូវមានលក្ខខណ្ឌពីរទៀត÷<br>ង_ ធ្វើយ៉ាងណាការចាក់សំណក់នៅផ្នែកមួយៗមិនមានការស្ទះ ធ្វើទៅ |

| | | |
|---|---|---|
| | | បានលឿនតាមដែលអាចធ្វើទៅបាន<br>ច_ ត្រូវកិនបង្ហាប់កុំឱ្យមានប្រហោង។ |
| | ការរៀបចំទំរង់គំនរសំណល់បែបខាងលើ អាចកាត់បន្ថយបរិមាណទឹកសំអុយទីលាន នាំឱ្យយើងអាចកាត់បន្ថយការចំណាយទៅលើការធ្វើប្រព្រឹត្តកម្មទឹកសំអុយទីលាន និងកាត់បន្ថយនូវហេតុប៉ះពាល់បរិស្ថាន។ | |
| **២.៦ ទឹកសំអុយទីលាន សំណល់រាវផ្សេងៗទៀត និងឧស្ម័ន** Leachate, other Waste Water and Gas | | |
| | ប្រភេទសំណល់រាវដែលកើតនៅទីលានមានដូចជា ÷<br>ក_ ទឹកសំអុយនៅស្រទាប់បាត ក៏ដូចជាទឹកសំអុយប្រមូលតាមប្រឡាយជុំវិញទីលាន<br>ខ_ ទឹកដែលហូរឆ្លងកាត់កន្លែងចាក់សំណល់ (landfill area) ដែលមិនទាន់មានសំណល់<br>គ_ ទឹកដែលហូរឆ្លងកាត់កន្លែងក្រាលបេតុងផ្សេងទៀត<br>ឃ_ សំណល់រាវដែលយកចេញពីកន្លែងប្រមូលផ្តុំ ពីមន្ទីរពិសោធន៍ កន្លែងផ្សេរ និងកន្លែងស្តុក។<br>ង_ ទឹកសំអុយហូរនៅលើផ្ទៃកចាក់សំណល់និមួយៗដែលបានគ្របហើយ<br>ច_ ទឹកពីខាងក្រៅដែលហូរចូលទីលាន (ទឹកផ្ទៃលើ ទឹកដែលគ្មានប្រភពច្បាស់លាស់)<br>ឆ_ សំណល់រាវចេញពីកន្លែងប្រើប្រាស់សំរាប់អនាម័យទូទៅ។<br><u>**ចំណាំ:**</u> ការបង្ហូរសំណល់រាវចេញ មិនត្រូវអោយហូរកាត់គំនរសំណល់ទេ។ | |

| ២.៧ ការត្រួតពិនិត្យ Checks | | |
|---|---|---|
| | ការត្រួតពិនិត្យ ធ្វើឡើងដោយអ្នកទទួលខុសត្រូវគ្រប់គ្រងទីលាន ឬក្រុមត្រួតពិនិត្យដែលទទួលកិច្ចការនេះ ដើម្បីអោយដឹងថា តើការសាងសង់ ការគ្រប់គ្រងទីលាន ប្រព័ន្ធក្រាលបាតទីលានធ្វើឡើងសមស្របតាមបទដ្ឋានបច្ចេកទេស ធានានូវការការពារគុណភាពទឹកក្រោមដីឱ្យបាន ឬអត់។<br>ដើម្បីធានាគុណភាពការត្រួតពិនិត្យខាងលើ ត្រូវធ្វើការពិនិត្យមើលឱ្យបានទៀងទាត់នូវទិន្នន័យដូចខាងក្រោមនេះ៖ | |
| | - កំពស់ទឹកភ្លៀង | - កំពស់ទឹកភ្លៀង<br>- បំរែបំរួលសីតុណ្ហភាព<br>- បំរែបំរួលល្បឿនខ្យល់ និង<br>- រំហួតទឹក<br>សំរាប់ទីលានអនាម័យនិងទីលានប្រកបដោយគ្រោះថ្នាក់ ត្រូវធ្វើការវិភាគនិងវាយតំលៃទៅលើ៖<br>- គុណភាពទឹក<br>- គុណភាពទឹកក្រោមដី ដោយមានយ៉ាងហោចមួយកន្លែងនៅផ្នែកខាងលើនៃទីតាំងភូមិសាស្ត្រទីលាន និងអាចមានច្រើនកន្លែងនៅផ្នែកខាងក្រោមនៃទីតាំងភូមិសាស្ត្រនៃទីលានតាមទិសចរន្តទឹកក្រោមដីហូរ ដោយត្រូវឱ្យច្បាស់ថា |

| | | |
|---|---|---|
| | | ទឹកក្រោមដីដែលហូរឆ្លងកាត់ក្រោមទីលានបានត្រួតពិនិត្យ។<br>- ការស្រុតចុះ និងការខូចទ្រង់ទ្រាយតំនរសំណល់ landfill body ។<br>- ការស្រុតចុះ និងការខូចទ្រង់ទ្រាយប្រព័ន្ធគំរបទីលាន landfill sealing systems ។ ក្នុងករណីមានសាយភាយឧស្ម័នទីលាន ត្រូវមានមធ្យោបាយក្នុងការវាស់ និងត្រួតពិនិត្យ។ ការត្រួពិនិត្យនិងវាយតំលៃនៃការសាយភាយឧស្ម័នត្រូវធ្វើឡើងដោយក្រុមគ្រប់គ្រងទីលានទាំងក្នុងពេលដំណើរការទីលាន និងក្រោយពេលបិទទីលាន។ |

ខ) តំរូវការទូទៅ និងតំរូវការជាមូលដ្ឋាននៅទីលាន

| អនុសាសន៍ តំរូវការ ឬភារកិច្ច | ប្រភេទទីលាន | | |
|---|---|---|---|
| | ទីលានបទដ្ឋានសាមញ្ញ | ទីលានអនាម័យ | ទីលានសំណល់ប្រកបដោយគ្រោះថ្នាក់ |
| **១. គោលការណ៍ទូទៅ** General Principle | | | |
| | | ទីលានមួយយ៉ាងហោចណាស់ត្រូវមាន ច្រកចូល (entrance area) កន្លែងបំពេញការងារ (ដូចជាកន្លែងស្តុកសំណល់ storage area, កន្លែងទទួលសំណល់ (receiving area) កន្លែងស្តុកសំណល់បណ្តោះអាសន្ន (interim storage area) ការិយាល័យការងារ (office), កន្លែងផ្ទេរ (transfer sites) | |

| | | |
|---|---|---|
| | | និងកន្លែងចាក់សំណល់ (lanfilling area)។ កន្លែងទាំងអស់ ត្រូវកំណត់ព្រំដែនច្បាស់លាស់។<br><br>ច្រកចូលយ៉ាងហោចត្រូវមាន÷<br>ក_ កន្លែងចតរថយន្តដឹកសំណល់ធំទូលាយ<br>ខ_ ការិយាល័យទទួលសំណល់ដោយមានជញ្ជីងថ្លឹងសំណល់មួយ<br>គ_ កន្លែងសំរាប់អធិការកិច្ចសំណល់សង្ស័យ (sampling bay) |
| | នៅតាមកន្លែងនិមួយៗ ត្រូវមានយ៉ាងហោចណាស់ សំភារៈបរិក្ខារសំរាប់ពន្លត់អគ្គីភ័យ ហើយទឹកដែលប្រើសំរាប់ពន្លត់អគ្គីភ័យ បើអាចធ្វើបានគួរតែរកមធ្យោបាយប្រមូលវាវិញ។ នៅគ្រប់កន្លែងដែលអាចកើតមានទឹកដែលរងការបំពុល ត្រូវក្រាលទប់ស្កាត់កុំឱ្យទឹកកខ្វក់នោះជ្រាបចូលក្នុងដី។ ការចាក់សំណល់លើទីលានត្រូវបង្ហាប់ឱ្យដល់កំរិតអតិបរមាដែលអាចធ្វើទៅបាន ប៉ុន្តែឱ្យសមស្របទៅនឹងសមត្ថភាពទីលាន។ | |
| **២. កន្លែងស្តុកបណ្តោះអាសន្ន** Interim Storage Areas | | |
| | | នៅលើទីលានអនាម័យត្រូវមានកន្លែងស្តុកបណ្តោះអាសន្ន (interim storage area) ដែលមិននៅជាមួយកន្លែងចាក់សំណល់ (landfilling area)។ កន្លែងនោះសំរាប់ធ្វើការញែកសំណល់ណាដែលត្រូវយកមកញែកមុននឹងយកទៅចោលនៅកន្លែងចាក់សំណល់ ដែលមានសមត្ថភាពយ៉ាងហោចណាស់សំរាប់សំណល់ ៣០០ម៉ែត្រគូប។ |

| | |
|---|---|
| ៣. **ទីតាំងទីលាន** Location | |
| | ទីលានមិនត្រូវសាងសង់នៅ ÷<br>ក_ តំបន់ណាដែលមានប្រហោង មិនមានលទ្ធភាពទប់ទល់នឹងការជ្រាប<br>ខ_ តំបន់ការពារទឹកស្អាតនាពេលបច្ចុប្បន្ននិងអនាគត<br>គ_ តំបន់ដែលជាកន្លែងលិចទឹក ឬអាចលិចទឹក<br>ឃ_ តំបន់ការពារសម្បត្តិធម្មជាតិ និងព្រៃឈើ<br>តំបន់ដែលជ្រើសយកសំរាប់ធ្វើទីតាំងសាងសង់ទីលានត្រូវគិតអំពី÷<br>ក_ ស្ថានភាពភូគព្ភសាស្ត្រ ធារាសាស្ត្រ លក្ខខ័ណ្ឌភូមិសាស្ត្រ និងទិសលំហូរទឹកក្រោមដី<br>ខ_ តំបន់ដែលអាចគ្រោះថ្នាក់ដោយសារការរញ្ជួយដី<br>ឃ_ តំបន់ដែលមិនមានដីបាក់ ស្រុត ឬកន្លែងអណ្តូងរ៉ែ។ |
| | បាតទីលានត្រូវមានតំលាតពីខ្សែទឹកក្រោមដីក្រោយពីចាក់សំណល់រួចយ៉ាងតិចបំផុត ១ម៉ែត្រ ហើយត្រូវធន់នឹងការផ្ទុកសំណល់ ដោយមិនធ្វើឱ្យគំនរសំណល់ landfill body បាក់ស្រុត។<br>ស្ថានភាពដីបាតទីលាន ត្រូវមានភាពរឹង មិនរហែកដែលមិននាំឱ្យបាក់ស្រុតខូចខាតដល់ប្រព័ន្ធក្រាលបាត និងភាពមានលំនឹងនៃគំនរសំណល់។ |

គ) បច្ចេកទេសរៀបចំប្រព័ន្ធបាតទីលាន

| អនុសាសន៍ តំរូវការ ឬកាតព្វកិច្ច | ប្រភេទទីលាន | | |
|---|---|---|---|
| | ទីលានបទដ្ឋានសាមញ្ញ | ទីលានអនាម័យ | ទីលានសំណល់ប្រកបដោយគ្រោះថ្នាក់ |
| **១. លក្ខណៈទូទៅ** General | | | |
| | ជាអនុសាសន៍ ប្រព័ន្ធបាតទីលានត្រូវរៀបចំដោយអនុលោមទៅតាមរូបភាពទី ១ និងទី ២នៅក្នុងឧបសម្ព័ន្ធនេះ។ អ្នកគ្រប់គ្រងទីលាន ត្រូវយកក្រុមហ៊ុនតែមួយសំរាប់ទទួលខុសត្រូវក្នុងការសាងសង់ប្រព័ន្ធក្រាលបាតទាំងមូល ឬផ្នែកណាមួយ។ | | |
| | ពេលសាងសង់ទ្រនាប់បាតទីលាន ត្រូវគណនាអោយបានត្រឹមត្រូវនិងត្រួតពិនិត្យអោយបានហ្មត់ចត់ (ឧទាហរណ៍ការគណនាទៅលើភាពលំអៀងនៅបរិវេណជុំវិញបំពង់បង្ហូរទឹកសំអុយ ឬឧស្ម័នជាដើម នៅពេលដំណើរការទីលានក្នុងករណីមាន)។ | | |
| **២. ប្រពន្ធ័ទ្រនាប់ក្រាលបាតទីលាន** Landfill base Lining Systems | | | |
| | ការក្រាលបាតទីលានត្រូវធ្វើទាំងបាត ទាំងជញ្ជាំងទេរ ហើយមិនអនុញ្ញាតអោយដាក់ ឬដោតរបស់អ្វីដែលអាចធ្វើឱ្យធ្លុះធ្លាយ ឬអាចឆ្លងកាត់ប្រព័ន្ធក្រាលបាតទីលោនទេ។<br>ស្រទាប់ភូគព្ភសាស្ត្រនៅបាតទីលានតម្រូវឱ្យមានលក្ខណៈដូចខាងក្រោមនេះ÷ | | |

| | | | |
|---|---|---|---|
| | - សារធាតុធម្មជាតិរបស់វានៅបាតទីលាននិងនៅជុំវិញ អាចទប់ស្កាត់ការជ្រាប និងការរាលដាលជាតិពុលបាន។<br>- មានសមត្ថភាពខ្ពស់ពីធម្មជាតិ អាចជ្រាបយ៉ាងតិចបំផុត ស្រូបយកសារធាតុពុលទុកមិនឱ្យទៅកន្លែងជុំវិញទីលាន។<br>- ត្រូវឱ្យវាមានភាពស្មើសាច់ដែលអាចទៅរួច។<br>ការសង់បាតទីលានត្រូវធ្វើជាបន្តបន្ទាប់ពីក្រោមឡើងលើ÷ | | |
| | - ជាអនុសាសន៍ស្រទាប់ភូគព្ភសាស្ត្រ ត្រូវរៀបចំឱ្យបានក្រាស់ជាង ៥០សង់ទីម៉ែត្រ និងមានមេគុណជម្រាបទឹក<br>k <1 x $10^{-8}$ m/s<br>- បាតទីលាន<br>- ត្រូវឱ្យមានចាក់ស្រទាប់ខនិជ ជាដីឥដ្ឋពីរជាន់ កំរាស់សរុបយ៉ាងតិច ៥០ សង់ទីម៉ែត្រ និងមេគុណជ្រាបទឹក<br>k <1 x $10^{-7}$ m/s<br>- ផ្ទៃលើនៃស្រទាប់ដីមានជម្រាលយ៉ាងហោចណាស់ | - ស្រទាប់ភូគព្ភសាស្ត្រ រៀបចំឱ្យបានក្រាស់ជាង ១០០ សង់ទីម៉ែត្រ និងមានមេគុណជម្រាបទឹក k <1 x $10^{-8}$ m/s<br>- បាតទីលាន<br>- ចាក់ស្រទាប់ខនិជ ជាដីឥដ្ឋបីជាន់ កំរាស់សរុបយ៉ាងតិច ៧៥សង់ទីម៉ែត្រ និងមានមេគុណជម្រាបទឹក<br>k <1 x $10^{-9}$ m/s<br>- ស្រទាប់សិនតេទិច (synthetic) ដែលមានកំរាស់ក្រាស់ជាង ២,៥មីលីម៉ែត្រ<br>- ផ្ទៃលើនៃស្រទាប់ដីមានជម្រាលយ៉ាង | - ត្រូវឱ្យមានស្រទាប់ភូគព្ភសាស្ត្រ (អាចតំឡើងតាមលក្ខណៈស៊ិនតេទិចបាន) ឱ្យបានក្រាស់ជាង ៣០០ សង់ទីម៉ែត្រ និងមានមេគុណជ្រាបទឹក<br>k <1 x $10^{-9}$ m/s<br>- បាតទីលាន<br>- ចាក់ស្រទាប់ខនិជ ជាដីឥដ្ឋបីជាន់ កំរាស់សរុបយ៉ាងតិច ៧៥ សង់ទីម៉ែត្រ និងមានមេគុណជ្រាបទឹក<br>k <1 x $10^{-9}$ m/s<br>- ស្រទាប់សិនតេទិច (synthetic) ដែលមានកំរាស់ក្រាស់ជាង ២,៥មីលីម៉ែត្រ<br>- ផ្ទៃលើនៃស្រទាប់ដីមានជម្រាលយ៉ាង |

| | | | |
|---|---|---|---|
| | ១ ភាគរយ ទៅតាមបណ្តោយទីលាន<br>- ធ្វើស្រទាប់ចំរោះទឹកមានមុខកាត់យ៉ាងហោច ៥០ សង់ទីម៉ែត្រ<br>មើលរូបទី ១ ក្នុងឧបសម្ព័ន្ធនេះ | ហោច ១ភាគរយ ទៅតាមបណ្តោយទីលាន<br>- ក្រាលស្រទាប់ការពារ<br>- ទ្រនាប់ចំរោះកំរាស់យ៉ាងហោច ៣០ សង់ទីម៉ែត្រ<br>- ដាក់បំពង់បង្ហូរទឹកសំអុយ។<br>មើលរូបទី ២ ក្នុងឧបសម្ព័ន្ធនេះ<br>ប្រព័ន្ធទ្រនាប់ក្រាលបាតសាងសង់ឡើងដូចរៀបរាប់ខាងលើ ឬក៏តាមប្រព័ន្ធស្រដៀង។ ត្រូវធ្វើវិភាគនូវមេគុណជំរាបទឹក k <1 x 10$^{-9}$ m/s ដោយយកសំណាកពី ៣០ កន្លែងទៅមន្ទីរពិសោធន៍។<br>អាចប្រើកៅស៊ូថ្នល់ជំនួសស៊ិនតេទិចដោយក្រាលជាពីរជាន់ ២ x ៦ សង់ទីម៉ែត្រ (១២សង់ទីម៉ែត្រ) ។ | ហោច ១ភាគរយទៅតាមបណ្តោយទីលាន<br>- ក្រាលស្រទាប់ការពារ<br>- ទ្រនាប់ចំរោះកំរាស់យ៉ាងហោច ៥០ សង់ទីម៉ែត្រ<br>- ដាក់បំពង់បង្ហូរទឹកសំអុយ<br>មើលរូបទី ២ ក្នុងឧបសម្ព័ន្ធនេះ<br>ត្រូវធ្វើវិភាគនូវមេគុណជំរាបទឹក k <1 x 10$^{-9}$ m/s ដោយយកសំណាកពី ៣០ កន្លែងទៅមន្ទីរពិសោធន៍។ |

| | | |
|---|---|---|
| | ការតំឡើងបំពង់សំរាប់ប្រមូលឧស្ម័ននិងទឹកសំអុយទីលានធ្វើយ៉ាងណាឱ្យអាចលាងសំអាត និងពិនិត្យបាន។<br>ត្រូវមានបំពង់បង្ហូរទឹកសំអុយទីលាន ហូរចេញដោយគ្មានឧបសគ្គទៅបំពង់ដែលតំឡើងខាងក្រៅទីលាន។<br>លើកដំបូង ស្រទាប់ខាងលើ ត្រូវមានជំរាលទទឹងយ៉ាងហោច ៣ភាគរយ និងតាមបណ្ដោយយ៉ាងហោច ១ភាគរយ។ | |
| | ស្រទាប់ចំរោះទឹកសំអុយនៅបាតទីលានត្រូវការពារកុំឱ្យកកស្ទះ។<br>ជាអនុសាសន៍ត្រូវមានមេគុណជ្រាបទឹកមិនតូចជាង $k = 1 \times 10^{-3}$ m/s។ | |
| **៣. ប្រព័ន្ធគម្របផ្ទៃខាងលើទីលាន** Landfill Surface Lining Systems | | |
| | ប្រព័ន្ធគម្របផ្ទៃខាងលើទីលានគឺ ត្រូវធ្វើនៅលើគំនរសំណល់ (landfill body) ក្រោយពេលផ្នែកមួយៗនៃទីលានសំណល់ត្រូវបានចាក់ពេញដោយសំណល់។ ហើយក្នុងករណីយើងមានបំណងចង់ដាំដុះរុក្ខជាតិនៅពីលើទីលានដែលគ្របរួច យើងត្រូវគិតគូរនូវតំរូវការបន្ថែម មានការចាក់ដីគ្របមួយស្រទាប់ទៀត និងមានស្រទាប់ការពារ។<br>ខាងក្រោមនេះជាតំរូវការមួយចំនួន៖<br>ក- ទ្រនាប់ខាងលើត្រូវកិនបង្ហាប់ស្មើសាច់ តែមិនប្រើសំភារៈដែលនាំគ្នាណែនតែម្ដងទេ ហើយកំរាស់មិនអោយក្រោម ០,៥០ ម៉ែត្រ។ | |
| | ខ- មិនមានការរៀបចំប្រព័ន្ធប្រមូលឧស្ម័នទីលាន<br>គ- ចាក់សារធាតុខនិជ ជាដីឥដ្ឋគ្របកំរាស់យ៉ាងហោច | ខ- ត្រូវតំឡើងប្រព័ន្ធប្រមូលឧស្ម័នដោយដាក់ផ្តេកនៅក្នុងស្រទាប់ដីចាក់ពង្រាបធ្វើគំរបពីលើសំណល់។<br>គ- ស្រទាប់ខនិជ ជាដីឥដ្ឋគ្រប ដែលមានកំរាស់យ៉ាងហោចណាស់អោយបាន ៥០សង់ទីម៉ែត្រ និងមានមេគុណជ្រាបទឹក $k = 1 \times 10^{-9}$ m/s។ |

| | | |
|---|---|---|
| | ណាស់ ២៥សង់ទីម៉ែត្រ ។ | នៅពីលើស្រទាប់ដីឥដ្ឋមានស្រទាប់ប្លាស្ទិកដែលមានកំរាស់យ៉ាងហោចណាស់ ២,៥មីលីម៉ែត្រ។ ដើម្បីការពារប្លាស្ទិក ត្រូវក្រាលស្រទាប់ការពារមួយទៀត។ |
| | ឃ_ ស្រទាប់ចំរោះនៅខាងលើស្រទាប់ការពារត្រូវមានកំរាស់យ៉ាងហោច ០,៣ម៉ែត្រ និងមានមេគុណជម្រាប $k = 1 \times 10^{-3}$ m/s ។<br>ង_ នៅស្រទាប់ដាំរុក្ខជាតិ ដើម្បីមិនអោយប៉ះពាល់ដល់ស្រទាប់គម្របការពារដោយសារឫស ត្រូវចាក់ដីកិនបង្ហាប់អោយស្មើសាច់ដោយមានកំរាស់មិនតិចជាង ១ម៉ែត្រ។ ការដាំរុក្ខជាតិវាមានអត្ថប្រយោជន៍ការពារខ្យល់ និងការសឹករិចរិល។ ការគិតគូរបានល្អិតល្អន់អំពីទិន្ន័យឧតុនិយម និងការជ្រើសរើសប្រភេទដំណាំរុក្ខជាតិ វានាំអោយយើងអាចការពារបានល្អនូវការជ្រាបទឹកចូលទៅក្នុងស្រទាប់ចំរោះ។ | |

## ឃ. បច្ចេកទេសចាំបាច់ក្នុងការរៀបចំការប្រមូលទឹកសំអុយ និងខ្ទស្នន័ទីលាន

| អនុសាសន៍ តម្រូវការ ឬកាតព្វកិច | ប្រភេទទីលាន | | |
|---|---|---|---|
| | ទីលានបទដ្ឋានសាមញ្ញ | ទីលានអនាម័យ | ទីលានសំណល់ប្រកបដោយគ្រោះថ្នាក់ |
| **១. ការប្រមូលនិងប្រព្រឹត្តកម្មទឹកសំអុយទីលាន** Leachate collection and treatment | | | |
| | ប្រព័ន្ធប្រមូលទឹកសំអុយទីលានត្រូវរៀបចំតាមបទដ្ឋានបច្ចេកទេសចាំបាច់ ដើម្បីធ្វើប្រព្រឹត្តកម្មទឹកសំអុយត្រូវមានអាងប្រព្រឹត្តកម្មសំណល់រាវ ដោយអនុលោមទៅតាមបទដ្ឋានច្បាប់ទាក់ទងការគ្រប់គ្រងសំណល់រាវ<br>ផែនការនៃដំណើរការប្រព្រឹត្តកម្មទឹកសំអុយត្រូវផ្អែកទៅលើបរិមាណនិងគុណភាពទឹកសំអុយទីលាននិមួយៗ ហើយនិតិវិធីប្រព្រឹត្តកម្មទឹកសំអុយ ត្រូវអនុវត្តទៅតាមច្បាប់ដែលបានកំណត់។ | | |
| | ទឹកសំអុយត្រូវបង្ហូរតាមប្រឡាយចូលទៅក្នុងអាងដែលស្ថិតនៅផ្នែកទំនាបនៃទីលាន។<br>ការធ្វើប្រព្រឹត្តកម្មទឹកសំអុយនៅក្នុងអាងមិនទាមទារឱ្យមានសកម្មភាពបញ្ចូលខ្យល់ គឺអនុវត្តតាមបែបធម្មជាតិមានជាអាទិ៍ ÷ | ការធ្វើប្រព្រឹត្តកម្មទឹកសំអុយទីលានអនាម័យនិងទីលានសំណល់ប្រកបដោយគ្រោះថ្នាក់តាមពិសោធន៍÷<br>– ការប្រើវិធីសាស្ត្រតែមួយមិនមានប្រសិទ្ធភាពដូចការប្រើវិធីសាស្ត្រចំរុះឡើយ។<br>– ក្នុងករណីយមានការប្រើវិធីសាស្ត្រប្រព្រឹត្តកម្មទឹកសំអុយចំរុះ ត្រូវមានការប្រុងប្រយ័ត្នទៅលើប្រសិទ្ធភាពនៃការសំអាត នៃវិធីសាស្ត្រមួយៗ ដែលអាចរំខានដោយវត្ថុមានសបាសធាតុនៅក្នុងទឹកសំអុយ។ | |

| | | |
|---|---|---|
| | - ដើម្បីកុំឱ្យក្រខ្វក់ បាតអាងនិងជុំវិញអាងមានក្រាលដោយទ្រនាប់ ឧទាហរណ៍ដូចជាទ្រនាប់ប្លាស្ទិក ។<br>- អាងប្រព្រឹត្តកម្មមានជំរៅពី ១ ម៉ែត្រ ទៅ ១,៥ ម៉ែត្រ។<br>- ការសាងសង់អាងប្រមូលទឹកសំអុយត្រូវគិតដល់បរិមាណទឹកភ្លៀង និងរយៈពេលស្ងួត។ | - ការប្រព្រឹត្តកម្មទឹកសំអុយត្រូវមានដំណើរការជាប្រចាំ ទោះបីទីលានបានបិទក៏ដោយ ព្រោះទឹកសំអុយនៅមានហូរបន្ត។ |
| **២. ការប្រមូលនិងប្រព្រឹត្តកម្មឬប្រើប្រាស់ឧស្ម័ន** Gas collection and treatment/utilisation | | |
| | មិនមានការទាមទារឱ្យមានការប្រមូលនិងធ្វើប្រព្រឹត្តកម្ម ឬប្រើប្រាស់ឧស្ម័នទេ។ | ការប្រមូលឧស្ម័នទីលានធ្វើទៅបានល្អហើយអស់ លុះត្រាតែមានការជួយទាញយក។<br>- សកម្មភាពតំឡើងប្រព័ន្ធប្រមូលឧស្ម័នទីលានត្រូវរៀបចំធ្វើឡើងតាំងពីពេលចាប់ផ្តើមដំណើរការទីលាន ហើយការប្រមូលឧស្ម័នអាចចាប់ផ្តើមអនុវត្តក្រោយពេលទីលានដំណើរការបានយ៉ាងតិច ៦ខែ។ ដើម្បីធានាការប្រមូលឧស្ម័នបានល្អប្រសើរ ចាំបាច់ត្រូវមានការរៀបចំប្រព័ន្ធប្រមូលឧស្ម័នសកម្មទាំងអស់បញ្ចូលគ្នា និងទាមទារឱ្យមានការត្រួតពិនិត្យ និងការថែទាំប្រព័ន្ធប្រមូលឧស្ម័ន។ |

| | | |
|---|---|---|
| | | - រយៈពេលនៃការវិវត្តន៍ឧស្ម័នទីលានត្រូវដឹងឱ្យបានច្បាស់លាស់ ដើម្បីរៀបចំប្រព័ន្ធ និងមធ្យោបាយប្រមូលព្រមទាំងការធ្វើប្រត្តិកម្ម។ តាមធម្មតាបរិមាណឧស្ម័នត្រូវបានគណនាដោយផ្អែកទៅលើការព្យាករណ៍ដែលជាលទ្ធផលនៃការសិក្សា ការត្រួតពិនិត្យ និងការវិនិច្ឆ័យនៅទីលានដែលមានស្រាប់។ |
| **២.១ ប្រព័ន្ធប្រមូលនិងតម្រូវការទូទៅ** Collection system and its general requirements | | |
| | | គោលបំណងចំបងក្នុងការប្រមូលឧស្ម័នទីលានគឺដើម្បីទប់ស្កាត់ការសាយភាយ ការបំពុល ក៏ដូចជាបញ្ចៀសនូវការបង្កគ្រោះថ្នាក់ និងការរំខានតាមរយៈឧស្ម័នទីលាន។ ប្រព័ន្ធប្រមូលឧស្ម័នទីលាន រៀបចំដោយប្រើឧបករណ៍ផ្សេងៗជាច្រើន÷<br>- ការប្រមូលឧស្ម័នទីលាន ត្រូវធ្វើយ៉ាងណាទប់ស្កាត់មិនឱ្យមានទឹកជ្រាបចូល ព្រោះនៅក្នុងតំនរសំណល់ទីលានតែងមានជាតិទឹក ហើយទឹកអាចធ្វើអោយមានភាពអសកម្មទាំងស្រុង ឬផ្នែកណាមួយក្នុងពេលប្រមូលយកឧស្ម័ន។ ដោយសារនៅក្នុងតំនរសំណល់ទីលានតែងមានជាតិទឹក ដូចនេះត្រូវមានការប្រមូលវាដោយឧបករណ៍ប្រមូល។<br>- ប្រព័ន្ធប្រមូលឧស្ម័នទីលានត្រូវតែមានដំណើរការគួរឱ្យទុកចិត្តបាន និងតម្រូវឱ្យមានការជួសជុលថែរក្សាតិចតួចបំផុត។ ចាំបាច់ត្រូវមានការដក |

| | | |
|---|---|---|
| | | ទឹកចេញ ដោយរៀបចំឱ្យងាយបូមចេញបាន។<br>- ប្រព័ន្ធប្រមូលឧស្ម័នទីលានមិនត្រូវធ្វើឱ្យប៉ះពាល់ដល់ប្រព័ន្ធទ្រនាប់ពិសេសក្នុងករណីប្រព័ន្ធប្រមូលឧស្ម័នដែលដាក់បញ្ឈរ ពីព្រោះនៅពេលដែលយើងចាក់សំណល់រឹង ខ្លះអាចបណ្តាលអោយមានការចាក់ធ្លាយប្រព័ន្ធទ្រនាប់។ ដូចនេះនៅពេលរៀបប្រព័ន្ធប្រមូលឧស្ម័នដែលដាក់បញ្ឈរ ត្រូវមានវិធានការសមស្របការពារកុំឱ្យមានការធ្លោះធ្លោយ។<br>- ប្រព័ន្ធប្រមូលឧស្ម័នត្រូវមានទ្រនាប់ការពារមិនអោយជ្រាបខ្យល់ពីក្រៅបាន។ ការចូលខ្យល់អាចធ្វើអោយកើតមាននូវល្បាយផ្ទុះបាន។ ឧបករណ៍ដែលកំពុងតំឡើងក៏ដូចជាតំឡើងរួចត្រូវធ្វើយ៉ាងណាកុំអោយមានខ្យល់ជ្រាបចូល។ |
| | | - សំភារៈប្រើសំរាប់តំឡើងប្រព័ន្ធប្រមូលឧស្ម័នទីលានត្រូវធន់នឹងប្រតិកម្មតាមលក្ខណៈរូប គីមី និងជីវៈ។ ប្រតិកម្មតាមលក្ខណៈរូបភាគច្រើនបានកើតឡើងនៅពេលដែលមានសីតុណ្ហភាពខ្ពស់ (រហូតដល់ប្រហែល ៧០ អង្សាសេ)។ ប្រតិកម្មគីមីកើតឡើងតាមរយៈឧស្ម័ន និងទឹកសំអុយទីលាន។ ប្រតិកម្មតាមរូបភាពជីវៈអាចបណ្តាលមកពីសកម្មភាពមីក្រូសរីរាង្គ។<br>- ការប្រមូលឧស្ម័នទីលាន ទាំងនៅកន្លែងកំពុងដំណើរការចាក់សំណល់ |

| | | |
|---|---|---|
| | | ទាំងកន្លែងចាក់រួចត្រូវសកម្មដូចគ្នា។ ដូច្នេះការតំឡើងនិងរៀបចំប្រព័ន្ធប្រមូលខុស្ម័នទីលានត្រូវធ្វើមិនឱ្យមានការរាំងស្ទះនិងរំខានក្នុងដំណើរការចាក់សំណល់ និងធានាមិនឱ្យមានការជ្រាបខ្យល់។<br>- ប្រព័ន្ធប្រមូលទឹកសំអុយមិនត្រូវប្រើប្រាស់ក្នុងគោលបំណងចំរាញ់យកឧស្ម័នទេ។ |
| **២.២ សំភារះប្រមូលឧស្ម័ន ប្រភេទនិងការរៀបចំ** Collection Elements, Types and Arrangements | | |
| | | ការតំឡើងប្រព័ន្ធទាញយកឧស្ម័នទីលានអាចជា៖<br>- បំពង់ប្រមូលឧស្ម័នដាច់ដោយឡែកពីគ្នា<br>- ការរៀបបំពង់បញ្ឈរជាប់គ្នា ឬបញ្ឈរជាជួរ<br>- ការរៀបបំពង់ផ្តេកជាប់គ្នា ឬបំពង់ផ្តេកជាជួរ<br>- ការដាក់ចំរុះរវាងប្រព័ន្ធផ្តេកនិងបញ្ឈរ<br>**ការតំឡើងបំពង់ប្រមូលឧស្ម័នដាច់ដោយឡែកពីគ្នា :**<br>បន្ទប់ប្រមូលឧស្ម័នរៀបចំឡើងក្រោយពេលទីលាន ឬកន្លែងទីលានចាក់សំណល់ណាមួយបិទ ប្រព័ន្ធនេះរៀបចំនៅក្នុងគំនរសំណល់ ដោយធ្វើការខួង ហើយរៀបជាបន្ទប់ការការបំពង់ឧស្ម័នដោយដាក់ដុំថ្មតូចៗជុំវិញ។ ប្រព័ន្ធប្រមូលយកឧស្ម័នបែបនេះមានភាពស្មុគស្មាញ ធ្វើឡើងតែក្នុងករណី |

| | | |
|---|---|---|
| | | លើកលែងណាមួយប៉ុណ្ណោះ។<br><br>**ការរៀបបំពង់បញ្ឈរជាប់គ្នា**<br>អនុវត្តនៅពេលដំណើរការទីលាន ដោយរៀបចំរណ្តៅជាបន្ទប់បំពេញដោយ ដុំថ្មតូចៗ ឬជាសំណល់សំណង់ជុំវិញបំពង់បញ្ឈរ ហើយនៅផ្ទៃមាត់ខាងលើ នៃរណ្តៅដែលរៀបជាបន្ទប់ត្រូវបិទឱ្យជិតមិនអោយឧស្ម័នជ្រាបចេញបាន និង ការពារមិនឱ្យខ្យល់ជ្រាបចូល។<br><br>**ការតំឡើងឧបករណ៍ប្រមូលឧស្ម័នដោយបំពង់បញ្ឈរជាផ្លូវ**<br>បន្ទប់ប្រមូលឧស្ម័នទីលាន ត្រូវមានមុខកាត់យ៉ាងហោច ២០០មីលីម៉ែត្រ ស្រោបជុំវិញសរសរដែលបំពេញដោយគ្រួស ឬថ្មតូចៗ ការពារដោយ ស្រទាប់សំណល់ម៉ដ្ឋ។ ស្រទាប់ការពារមានកំរាស់ ១០ភាគរយ ទៅ ១៥ភាគរយ នៃកំពស់សរសរសរុប ឬយ៉ាងហោចណាស់ ២ម៉ែត្រ។ សំភារៈដែលប្រើចាក់ក្នុងសរសរគឺមានលក្ខណៈជាគ្រាប់មានទំហំ ១៦/៣២ មានសមាសធាតុកាបោនមិនឱ្យលើសពី ១០ភាគរយ គិតជាទំងន់។ តំលាត ពីផ្ទៃខាងលើអតិបរមា ២ម៉ែត្រ។ ដើម្បីជៀសវាងការរបួតតំណបំពង់ប្រមូល ឧស្ម័ន ត្រូវប្រើតំណដែលឱ្យបំពង់ប្រមូលឧស្ម័នអាចរំកិលឡើងលើចុះ ក្រោមបាន។ |

| | | |
|---|---|---|
| | | **ការរៀបបំពង់ផ្ដេកជាប់គ្នា**<br>ស្រទាប់ប្រមូលឧស្ម័នសង់ឡើងនៅក្នុងតំនរសំរាម ដោយប្រើសំណល់ប្រភេទមួយសបស្របជំនួសកំទេចថ្ម ដើម្បីដើរតួជាចម្រោះឧស្ម័ន និងឧស្ម័នអាចឆ្លងកាត់ងាយស្រួល និងមានជម្រាលយ៉ាងហោច ៥ភាគរយ។<br>**ការរៀបបំពង់ផ្ដេកជាជួរ**<br>ប្រព័ន្ធប្រមូលឧស្ម័នបែបនេះ ងាយនឹងរំខានដោយទឹកសំអុយ។ ការសង់ត្រូវធ្វើអោយមានជម្រាលយ៉ាងហោច ៧ភាគរយ សំភារៈ និងនៅពេលសាងសង់ ត្រូវតែធ្វើការពិចារណាទៅលើមធ្យោបាយត្រួតពិនិត្យនិងប្រព័ន្ធប្រមូលសំអាតសំរាប់រយៈពេលយូរអង្វែង។<br>សំភារៈបំពង់បង្ហូរឧស្ម័នធ្វើអំពីប្លាស្ទិកត្រូវធន់នឹងកំដៅ និងមានមុខកាត់ធំជាង ២៥០មីលីម៉ែត្រ។ ការសាងសង់ប្រព័ន្ធបែបនេះ ក៏ត្រូវគោរពតាមល័ក្ខខ័ណ្ឌខាងលើដែរ គឺដូចជាការរៀបចំសរសរដែលមានថ្មតូចៗការពារ។<br>ក្នុងករណីការរៀបបំពង់ផ្ដេកជាជួរនេះ ទីធ្លាផ្ដេកត្រូវមានទំហំជាមធ្យម ៣០ម៉ែត្រ និងទំហំទីធ្លាបញ្ឈរជាមធ្យមពី ៣០ម៉ែត្រ។<br>**ការដាក់ចំរុះរវាងប្រព័ន្ធផ្ដេកនិងបញ្ឈរ**<br>ការរៀបចំប្រព័ន្ធបញ្ឈរថែមទៅលើប្រព័ន្ធផ្ដេក នៅកន្លែងណាដែលមានការ |

| | | |
|---|---|---|
| | | ប្រមូលឧស្ម័នសក្តានុពលខ្ពស់។ ឧទាហរណ៍ប្រព័ន្ធបញ្ឈរមានតួនាទីប្រមូលឧស្ម័នដែលហូរឆ្លងកាត់សរសរចំរោះនៃប្រព័ន្ធផ្តេក។ |
| **២.៣ ការត្រួតពិនិត្យការប្រមូលឧស្ម័ននិងតម្រូវការទូទៅ** Gas collection control and general requirements | | |
| | | តួនាទីចំបងក្នុងការប្រមូលឧស្ម័ន និងត្រួតពិនិត្យប្រព័ន្ធប្រមូលឧស្ម័នគឺ៖<br>- ធ្វើយ៉ាងណាឱ្យឧបករណ៍សំរាប់ប្រមូល មានសុពលភាពខ្ពស់ក្នុងការប្រមូលឧស្ម័នទីលាន និងជៀសវាងការសាយចេញពីទីលាន។<br>- កាត់បន្ថយឱ្យដល់កំរិតអប្បរមា នូវវត្តមានសមាសភាពខ្យល់ក្នុងឧស្ម័នទីលាន ដោយនៅកន្លែងក្បាលបញ្ចេញឧស្ម័ននៃបំពង់បង្ហូរ ត្រូវធ្វើយ៉ាងណាអាចបើកបិទទៅបានតាមសំពាធឧស្ម័ន។ នៅក្បាលបញ្ចេញឧស្ម័ននៃបំពង់បង្ហូរ ត្រូវមានសមត្ថភាពដល់កំរិត p = 3 kPa (30 mbar)។ ល្បឿនលំហូរនៃឧស្ម័ននៅក្នុងបំពង់ប្រមូលឧស្ម័នត្រូវនៅក្រោម ១០ម៉ែត្រក្នុងមួយវិនាទី។ រាល់មធ្យោបាយខាងលើត្រូវបានវាយតំលៃ អំពីសុវត្ថិភាពដោយក្រុមជំនាញ និងអ្នកមានការទទួលស្គាល់។ |

| ២.៤ ប្រព័ន្ធប្រមូល និងប្រព័ន្ធត្រួតពិនិត្យ Collection and control system | | |
|---|---|---|
| | | **លក្ខណៈទូទៅ**<br>ប្រព័ន្ធប្រមូលឧស្ម័នទីលាន តែងតែទទួលនូវឥទ្ធិពលប្រតិកម្មបែបរូប គីមីនិងជីវៈ។ ដូចនេះក្នុងការសាងសង់ប្រព័ន្ធប្រមូលឧស្ម័នទីលាន យើងត្រូវជ្រើសរើសសំភារៈដោយពិនិត្យទៅលើកត្តាទាំងបីខាងលើ។<br>តាមរយៈការស្រុតនៃគំនរសំណល់ និងកំដៅ វានឹងអាចធ្វើឱ្យខូចទ្រង់ទ្រាយបណ្តាញបំពង់ប្រមូលឧស្ម័ន។<br>• ដើម្បីជៀសវាងកុំឱ្យមានកើតឡើងនូវការបោ៉ង ឬផតនៅកន្លែងណាដែលមានការស្រុតនៃគំនរសំណល់ យើងត្រូវរៀបបំពង់បង្ហូរជម្រាលយ៉ាងហោចណាស់អោយបាន ៥ ភាគរយ បើនៅក្រោមគំនរសំណល់ ឬ ២,៥ភាគរយបើនៅលើដីគំនរសំណល់។<br>• ការធ្វើការផ្លាស់ទី (បំរែបំរួល) នៃបំពង់ប្រមូលឧស្ម័ននៅក្នុងទីលានទាំងផ្ទរផ្តេកទាំងផ្ទរបញ្ឈរមិនត្រូវឱ្យប៉ះពាល់នៅត្រង់ដំណទេ។<br>• ស្ថានីយកណ្តាលប្រមូលឧស្ម័នទីលាន និងស្ថានីយរងត្រូវតំឡើងនៅលើដីដែលទ្រាំទ្របាន។<br>• ឧបករណ៍ដែលប្រើប្រាស់ក្នុងស្ថានីយកណ្តាលទាមទារឱ្យមានគុណភាពនិង |

| | | |
|---|---|---|
| | | មានសុវត្ថិភាព (ធន់នឹងសព្វាធ បិទចម្លងចរន្តអគ្គិសនី ធន់នឹងកំដៅ។ ដើម្បីសុវត្ថិភាពពេលដំណើរការ និងកាត់បន្ថយការបាត់បង់សម្ពាធឧស្ម័ន បំពង់ផ្នែកខាងក្នុងត្រូវមានមុខកាត់តូចបំផុត ១០០មីលីម៉ែត្រ។<br>**ប្រព័ន្ធទទួលឧស្ម័ន**<br>ប្រព័ន្ធទទួលឧស្ម័នទីលានភ្ជាប់ (បញ្ជូន) ទៅស្ថានីយកណ្តាលដោយផ្ទាល់ឬ ទៅកន្លែងទទួលជាអន្តរកាល។ ក្នុងករណីបំពង់ទទួលឧស្ម័នយទីលាននៅដាច់តែឯង ត្រូវភ្ជាប់វាទៅស្ថានីយកណ្តាលផ្ទាល់តែម្តង។<br>បំពង់ប្រមូលឧស្ម័នតជាក្រុម ត្រូវភ្ជាប់វាទៅស្ថានីយមួយ (កន្លែងទទួលឧស្ម័នជាអន្តរកាល) ហើយភ្ជាប់បន្តទៅស្ថានីយកណ្តាល។ |
| | | **ដំណើរការត្រួតពិនិត្យ**<br>ការត្រួតពិនិត្យត្រូវធ្វើឡើងទៅលើបរិមាណ និងគុណភាពនៃឧស្ម័ន និងប្រៀបធៀបតំលៃដែលបានគិតទុកជាមុន។<br>ការអង្កេតតាមដានត្រួតពិនិត្យភាពបំរែបំរួលនៃឧស្ម័នទីលានត្រូវធ្វើយ៉ាងតិចមួយដងក្នុងមួយសប្តាហ៍។ |

| | | |
|---|---|---|
| **២.៥ ការញែកទឹកនៅក្នុងឧស្ម័ន** Condensate separation | | |
| | | ចំហាយទឹកដែលបានចូលលាយឡំជាមួយឧស្ម័នទីលានក្លាយជាកំណកទឹក ធ្លាក់នៅក្នុងប្រព័ន្ធបំពង់ប្រមូលឧស្ម័នទីលាន ដូច្នេះត្រូវធ្វើការត្រួតពិនិត្យយ៉ាងទៀងទាត់។ មូលដ្ឋាននៃការវាស់ឱ្យដឹងនូវបរិមាណទឹកនៅក្នុងឧស្ម័ន ពី គេបញ្ចុះសីតុណ្ហភាពពី ៥៥ អង្សាសេ ទៅ ២០ អង្សាសេ។ ការគ្រប់គ្រងកំណក ត្រូវពឹងផ្អែកទៅលើបច្ចេកទេសសមស្របនាពេលបច្ចុប្បន្ន។ នៅក្នុងករណីជាច្រើន អនុញ្ញាតឱ្យគ្រប់គ្រងជាមួយទឹកសំអុយ។ |
| **២.៦ ការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពក្នុងការបូមឧស្ម័ន** Monitoring the efficiency of degasing | | |
| | | ការសាយភាយឧស្ម័នទីលានចេញតាមគម្របផ្ទៃខាងលើទីលានទៅផ្នែកបរិយាកាសខាងក្រៅមិនត្រូវឱ្យមាន ឬយ៉ាងហោចណាស់ក៏បានកាត់បន្ថយឱ្យដល់កំរិតមួយទាបបំផុត។<br><br>**ទីលានចំហ ឬផ្នែកផ្សេងទៀតនៃទីលានចំហ**<br>ការត្រួតពិនិត្យការប្រមូលយកឧស្ម័នទីលានត្រូវធ្វើឡើងរៀងរាល់សប្តាហ៍ ដោយអ្នកដំណើរការទីលាន និងរៀងរាល់៣ខែម្តងត្រូវធ្វើឡើងដោយក្រុម |

| | | |
|---|---|---|
| | | ឯកទេសមួយ និងចំពោះទីលានចំហ ឬផ្នែកនៃទីលានចំហ ការត្រួតពិនិត្យការប្រមូលឧស្ម័នទីលាននៅទ្រនាប់ចុងក្រោយតាមជើងទីលាន ត្រូវធ្វើឡើង ៦ខែម្តង។<br><br>**ការគ្របទ្រនាប់ចុងក្រោយនៃទីលានឬផ្នែកនៃទីលាន**<br>ដើម្បីឱ្យការប្រមូលឧស្ម័នប្រកបដោយប្រសិទ្ធភាព រាល់៦ខែម្តងត្រូវមានការត្រួតពិនិត្យដោយក្រុមបច្ចេកទេស។ ជៀសវាងការសាយភាយឧស្ម័នទីលានលើស្រទាប់គម្របដីដាំរុក្ខជាតិ និងផ្នែកជុំវិញទីលានត្រូវមានការត្រួតពិនិត្យ។ |




**រូបទី១** ប្រព័ន្ធបាតក្រោមទីលានបចន្លានសាមញ្ញ




**រូបទី២** ប្រព័ន្ធបាតក្រោមទីលានអនាម័យ និងទីលានសំរាប់សំណល់ប្រកបដោយគ្រោះថ្នាក់

## ឧបសម្ព័ន្ធ ៧ កម្រិតកំណត់លោហៈធ្ងន់ក្នុងសំណល់គក់ដែលយកទៅធ្វើជីកំប៉ុស្តិ៍

| ប៉ារ៉ាម៉ែត្រ | កម្រិតកំណត់ (mg/kg) ស្ងួត |
|---|---|
| កាត់ញ៉ូម | ≤ ២០ |
| ក្រូម | ≤ ១០០០ |
| បារ៉ត | ≤ ១៦ |
| នីកែល | ≤ ៣០០ |
| សំណ | ≤ ៧៥០ |
| ទង់ដែង | ≤ ១០០០ |
| ស័ង្កសី | ≤ ២៥០០ |

## ឧបសម្ព័ន្ធ ៨ លោហៈធ្ងន់ដែលអនុញ្ញាតឱ្យមាននៅក្នុងជីកំប៉ុស្តិ៍

| ប៉ារ៉ាម៉ែត្រ | កម្រិតកំណត់ (mg/kg) ស្ងួត |
|---|---|
| កាត់ញ៉ូម | ≤ ១,៥ |
| ក្រូម | ≤ ១៥០ |
| បារ៉ត | ≤ ១ |
| នីកែល | ≤ ១០០ |
| សំណ | ≤ ១៥០ |
| ទង់ដែង | ≤ ២៣០ |
| ស័ង្កសី | ≤ ៤០០ |

ឧបសម្ព័ន ៩ គំរូនៃការបច្ចេកទេសសំរាប់មធ្យោបាយប្រព្រឹត្តកម្មជីវៈ

១. ការធ្វើប្រព្រឹត្តកម្មសំណល់ជីវៈ

ក្នុងការធ្វើប្រព្រឹត្តកម្មលើសំណល់ជីវៈគឺក្នុងវត្ថុបំណងសំខាន់ពីរ ÷

- ធ្វើប្រព្រឹត្តកម្មទៅលើសំណល់នៅលាយច្របូកច្របល់គ្នា ឬសំណល់ចុងក្រោយ ដែលបំរុងនឹងយកទៅចាក់ចោលនៅទីលាន។ ការធ្វើប្រព្រឹត្តកម្មលើសំណល់នេះ គឺក្នុងបំណងធ្វើឱ្យមានលំនឹងជីវៈ មុននឹងយកវាទៅចាក់ចោលនៅទីលាន ដោយកាត់បន្ថយបរិមាណសំណល់ ទឹកសំអុយ និងឧស្ម័នមេតាន។
- ធ្វើប្រព្រឹត្តកម្មលើសំណល់ជីវៈ (ការធ្វើជីកំប៉ុស្ដិ៍) ដើម្បីផលិតជីកំប៉ុស្ដិ៍ ប្រើក្នុងវិស័យកសិកម្ម ស្រែចំការ និងសំរាប់ដីដាំដើមឈើលំអ។

នៅក្នុងឧបសម្ព័ន្ធនេះយើងលើកយកតែអនុសាសន៍ស្ដីពីការធ្វើជីកំប៉ុស្ដិ៍ទេ÷

១.១ លក្ខខ័ណ្ឌធ្វើប្រព្រឹត្តកម្មសំណល់ជីវៈប្រភេទផ្សេងៗ

សំណល់ជីវៈទាំងអស់មិនមានកំរិតសមាសធាតុទឹក ឬភាពហើមប៉ោងដូចគ្នាទេ។ សំណល់ជីវៈខ្លះមានសមាសធាតុទឹកខ្ពស់ មានភាពហើមប៉ោង និងធ្វើការបំបែកធាតុលឿន (ដូចជាសំណល់អាហារ សំណល់ភក់ជាដើម) និងសំណល់ខ្លះទៀត មានសមាសធាតុទឹកតិច ឬមិនងាយធ្វើការបំបែកធាតុ (ដូចជាសំណល់សួនច្បារជាដើម)។ ដូចនេះជាអនុសាសន៍ ដើម្បីឱ្យដំណើរការធ្វើជីកំប៉ុស្ដិ៍បានល្អ លក្ខខ័ណ្ឌមួយចំនួនខាងក្រោមត្រូវបំពេញ÷

- ដើម្បីជៀសវាងនូវការរំខានដោយក្លិន សំណល់ដែលមានភាពហើមប៉ោងស្អុយរលួយមានកម្រិតខ្ពស់ (ដូចជាសំណល់ភក់ សំណល់អាហារ។ល។) ទទួលការអនុញ្ញាតឱ្យស្តុកទុករយៈពេលតែ ២ថ្ងៃ ហើយយ៉ាងយូរបំផុត ៥ថ្ងៃប៉ុណ្ណោះ។
- ទីកន្លែងសំរាប់មធ្យោបាយធ្វើប្រព្រឹត្តកម្មសំណល់ប្រភេទខាងលើនេះ ធ្វើនៅក្នុងកន្លែងមួយដែលបិទជិតមាន÷
    - កន្លែងបញ្ចូនសំណល់ចូល
    - កន្លែងដំណើរការធ្វើជីកំប៉ុស្ដិ៍មានរយៈពេលដល់អាទិត្យទី ៤។
- ការតព្វកិច្ចទៅលើដំណើរការធ្វើជីកំប៉ុស្ដិ៍ក្នុងលក្ខខ័ណ្ឌខាងលើមិនទាមទារ ក្នុងករណី

- ធ្វើប្រព្រឹត្តកម្មទៅលើសំណល់រុក្ខជាតិ ដូចជាកំទិចកំទីឈើ និងសំណល់សួនច្បារសុទ្ធ។
- តំរូវការសំរាប់មធ្យោបាយធ្វើជីកំប៉ុស្តិ៍ យោងទៅតាមទីតាំងទីលាន និងសមត្ថភាពប្រព្រឹត្តកម្ម ដូចជា៖
  - សមត្ថភាពសំរាប់វត្ថុធាតុដើមដែលតិចជាង ១០០០ តោនក្នុងមួយឆ្នាំ និងស្ថិតនៅចំងាយឆ្ងាយជាង ៥០០ ម៉ែត្រ ពីលំនៅដ្ឋាន។
  - សមត្ថភាពសំរាប់វត្ថុធាតុដើមដែលតិចជាង ៣០០០ តោនក្នុងមួយឆ្នាំ និងស្ថិតនៅចំងាយឆ្ងាយជាង ១០០០ ម៉ែត្រ ពីលំនៅដ្ឋាន។
  - សមត្ថភាព សំរាប់ វត្ថុធាតុ ដើម ដែល តិច ជាង ៦០០០ តោន ក្នុងមួយឆ្នាំ និងស្ថិតនៅចំងាយឆ្ងាយ ១០០០ម៉ែត្រពីលំនៅដ្ឋាន ក្នុងករណីការរៀបចំពំនូកសំណល់ជាប្រព័ន្ធស្តាទិកនៅក្នុងដំណើរការធ្វើជីកំប៉ុស្តិ៍ដំណាក់ការដំបូង។ ករណីយនេះកន្លែងចាក់សំណល់និងកន្លែងធ្វើប្រព្រឹត្តកម្មបឋមនោះយ៉ាងណាក៏ដោយគឺ ត្រូវតែបិទជិត។

## ១.២ ការគ្រប់គ្រងដំណើរការធ្វើជីកំប៉ុស្តិ៍

ដើម្បីឱ្យដំណើរការធ្វើជីកំប៉ុស្តិ៍ទទួលបានជោគជ័យ អ្នកគ្រប់គ្រងត្រូវអនុវត្តនូវមធ្យោបាយមួយចំនួនដូចជា៖

- ការបញ្ចូលខ្យល់ធ្វើដោយបូមបញ្ចូល ឬស្រូប។ ការបញ្ចូលខ្យល់ធ្វើឱ្យបានយ៉ាងតិច ១៥ម៉ែត្រគូបក្នុងមួយម៉ោង ក្នុងមួយតោននៃសំណល់ស្រស់។ រយៈពេលបិទកង្ហារមិនត្រូវយូរជាង ៣០ នាទីទេ។
- ចំពោះដំណើរការធ្វើជីកំប៉ុស្តិ៍ទៅលើសំណល់រុក្ខជាតិ ឬសំណល់សួនច្បារ ដោយមានទ្រង់ទ្រាយតូច និងមានការគ្រប (មានកំពស់អតិបរមាពី ១៥០ ទៅ ២០០ សង់ទីម៉ែត្រ) ការបញ្ចូលខ្យល់ធ្វើឡើងដោយមិនសកម្ម តាមរយៈការប្រើបំពង់ខ្យល់។

- កំពស់អតិបរមានៃរងសំណល់ នៅដំណាក់ការសកម្មគឺ ២.៥០ ម៉ែត្រ សំរាប់ប្រព័ន្ធស្តាទិក និង ៣ម៉ែត្រ សំរាប់ប្រព័ន្ធឌីណាមិក។
- ក្នុងករណីយដំណើរការដែលរងស្តាទិកមានការគ្រប ត្រូវលាយវត្ថុធាតុដើមស្ងួត ៥០ ភាគរយ (ដូចជាសំណល់សួនច្បារ កំទិចកំទីឈើជាដើម)។
- ត្រូវមានឧបករណ៍សំរាប់ត្រួតពិនិត្យដំណើរការ (យ៉ាងហោចណាស់ក៏មានប្រដាប់ស្ទង់សីតុណ្ហភាពដែរ)។
- រៀបចំឱ្យមានប្រព័ន្ធផ្សើមសំណល់ យ៉ាងហោចណាស់ក៏មានប្រព័ន្ធផ្សើមនៅក្នុងដំណាក់កាលសកម្មដែរ។

## ១.៣ ការគ្រប់គ្រងសំណល់រាវ

មធ្យោបាយគ្រប់គ្រងសំណល់រាវត្រូវមាននៅលើកន្លែងធ្វើជីកំប៉ុស្តិ៍ទាំងមូល។ ការក្រាលបាតត្រូវធ្វើឡើងនៅគ្រប់កន្លែងប្រតិបត្តិទាំងអស់ ទាំងកន្លែងចាក់សំណល់ កន្លែងស្តុកទុក កន្លែងធ្វើប្រព្រឹត្តកម្មបឋម កន្លែងដែលសំណល់ចាប់ផ្តើមធ្វើការហើម កន្លែងកំប៉ុស្តិ៍សកម្ម កន្លែងក្រោយកំប៉ុស្តិ៍សកម្ម កន្លែងធ្វើប្រព្រឹត្តកម្មចុងក្រោយ មិនឱ្យជ្រាបទឹកចូលទៅទឹកក្រោមដីបាន។

កន្លែងធ្វើប្រព្រឹត្តកម្មលើសំណល់កំទិចកំទីឈើ និងសំណល់សួនច្បារដែលមានបរិមាណ ១០០០ តោនក្នុងមួយឆ្នាំ មិនចាំបាច់មានការក្រាលបាតទីលានទេ។ ក្នុងករណីយនេះ ស្រទាប់ចំពោះគួរប្រើរនាបឈើ ដើម្បីជៀសវាងភក់ជ្រាំ ជៀសវាងការលាយថ្ម និងសារធាតុខនិជផ្សេងទៀតនៅក្នុងជីកំប៉ុស្តិ៍។

ក្នុងករណីមានចាក់សាប ត្រូវរៀបចំការគ្រប់គ្រងទឹកសំអុយ និងប្រព័ន្ធស្តុកឱ្យបានត្រឹមត្រូវ។

### ១.៣.១ ទឹកសំអុយចេញពីដំណាក់កាលកំប៉ុស្តិ៍សកម្ម

ទឹកសំអុយដែលចេញពីដំណាក់កាលកំប៉ុស្តិ៍សកម្ម និងកន្លែងទទួលសំណល់ ជាការប្រសើរត្រូវយកមកកែច្នៃប្រើប្រាស់ឡើងវិញ ក្នុងដំណើរការធ្វើជីកំប៉ុស្តិ៍ ជាជាងការយកវាទៅកន្លែងធ្វើប្រព្រឹត្តកម្មទឹក។

ការប្រើប្រាស់ឡើងវិញនូវទឹកសំអុយដែលបានមកពីកន្លែងធ្វើជីកំប៉ុស្តិ៍បិទជិត ត្រូវធ្វើឡើងនៅលើគំនរសំណល់នៅកន្លែងបិទជិត ដោយសារតែការវិខានពីសក្តានុពលនៃការបញ្ចេញក្លិនខ្លាំង។

ការរៀបចំអាងស្តុកសំណល់រាវត្រូវប្រើរូបមន្តសំរាប់គណនាសមត្ថភាព (ចំណុះ) អាងដូចតទៅ៖

$$C = R \times Q \times T : 1000$$

ដែល

- C = ទំហំអាងស្តុកគិតជាម៉ែត្រគូប
- R = មេគុណកំណើនទឹកសំអុយ

  ជាធម្មតា ២ < R < ៥ ជាមួយការបញ្ចូលខ្យល់កិរិតទាប
- Q = បរិមាណសំណល់ជីវៈមួយលើកនៅក្នុងដំណាក់កាលកំប៉ុស្តិ៍សកម្ម
- T = រយៈពេល (ចំនួនថ្ងៃ) នៃការបញ្ចេញទឹកសំអុយរបស់សំណល់

### ១.៣.២ ទឹកសំអុយដែលចេញពីការធ្វើប្រព្រឹត្តកម្មក្លិននិងនៅកន្លែងដំណាក់ក្រោយកំប៉ុស្តិ៍សកម្ម

ទឹកសំអុយនេះត្រូវប្រើប្រាស់ឡើងវិញទៅលើគំនូកសំណល់ដែលនៅក្នុងដំណាក់កាលកំប៉ុស្តិ៍សកម្ម។ ដើម្បីគណនាសមត្ថភាព (ចំណុះ)អាងស្តុកទឹកសំអុយនេះយើងអាចប្រើរូបមន្ត

$$Q = S * (P:1000) / 30,$$

ដែល

- Q = ទំហំអាងស្តុកគិតជាម៉ែត្រគូប
- S = ទំហំកន្លែងសំអាតចុងក្រោយគិតម៉ែត្រការ៉េ
- P = កំពស់ទឹកភ្លៀងគិតជាមីលីម៉ែត្រក្នុង ១ឆ្នាំ

ដូច្នេះតាមបទពិសោធន៍គឺ ប្រហែល ១ម៉ែត្រគូប/ ៣០ម៉ែត្រការ៉េ ចំពោះកំពស់ទឹកភ្លៀង ១ម៉ែត្រ។

### ១.៣.៣ ទឹកភ្លៀង

ទឹកភ្លៀងនៅកន្លែងរថយន្តដឹកសំណល់ឆ្លងកាត់ (រាប់បញ្ចូលកន្លែងសំអាតចុងក្រោយ) ទាំងអស់ត្រូវស្តុកទុក ដើម្បីយកទៅប្រើប្រាស់ទាំងនៅក្នុងដំណាក់កាលកំប៉ុស្តិ៍សកម្មនិងដំណាក់កាលចុងក្រោយ។

ជាអនុសាសន៍ក្នុងនេះយើងនិយាយតែទឹកភ្លៀង នៅកន្លែងរថយន្តដឹកសំណល់ឆ្លងកាត់ (មិនរាប់បញ្ចូលកន្លែងសំអាតចុងក្រោយ)។

ចំពោះទឹកភ្លៀងដែលធ្លាក់ដំបូង ត្រូវបំបែកចេញពីទឹកភ្លៀងលើកទី២ ដែលអាចយកទៅប្រើប្រាស់ទាំងនៅក្នុងដំណាក់កាលកំប៉ុស្តិ៍សកម្មនិងដំណាក់កាលក្រោយកំប៉ុស្តិ៍សកម្ម។ ចំណែកទឹកភ្លៀងលើកទី ២ អាចបញ្ចេញទៅតាមស្រះប្រឡាយ ឬបឹងទន្លេបាន។

រូបមន្តសំរាប់គណនាបរិមាណទឹកភ្លៀងដំបូងដែលត្រូវស្តុកទុកគឺ ÷

$$C = (S \times P) /(1000)$$

ដែល

- $C$ = បរិមាណទឹកភ្លៀងដំបូងដែលត្រូវស្តុកទុកគិតជាម៉ែត្រគូប
- $S$ = ផ្ទៃកន្លែងរថយន្តដឹកសំណល់ឆ្លងកាត់ គិតជាម៉ែត្រការ៉េ
- $P$ = កំពស់ទឹកភ្លៀងដំបូងស្មើនឹង ៥ មីលីម៉ែត្រ

### ១.៣.៤ ទឹកដែលរងការបំពុល

ទឹកទាំងនេះត្រូវបញ្ចេញទៅកន្លែងធ្វើប្រព្រឹត្តកម្មសំណល់រាវ ឬត្រូវធ្វើទៅតាមបទបញ្ញត្តិគ្រប់គ្រងសំណល់រាវ។

### ១.៣.៥ ទឹកចេញពីការលាងសំអាតម៉ាស៊ីន

ទឹកនេះអាចត្រូវបញ្ចេញដោយអនុលោមទៅតាមបទបញ្ញាតិគ្រប់គ្រងសំណល់រាវដែរ។

## ១. ៤ ការគ្រប់គ្រងភាពសាយភាយខ្យល់

- ដើម្បីសុវត្ថិភាពក្នុងការកាត់បន្ថយការសាយភាយនៃក្លិន និងហេតុប៉ះពាល់បរិស្ថាន ក្នុងអាគារបិទជិតនៅកន្លែងណាក៏ដោយចាំបាច់ត្រូវតែមានឧបករណ៍ប្រមូល និងបូមខ្យល់ ដើម្បី

បន្ទយក្លិន។

- ក្នុងការបូមយកក្លិនចេញត្រូវឆ្លងកាត់នូវតំរងជីវៈ ដែលមានតួនាទីសំអាតខ្យល់។
- តំរងជីវៈធ្វើឡើងតាមតំរូវការខាងក្រោមនេះ៖

- អាចទ្រាំទ្របានកំលាំង 100 $Nm^3/m^3$ ឬក៏តិចជាង
- រយៈពេលបង្ខាំងទុក ៣៦វិនាទី ឬក៏លើសពីនេះ
- កំពស់នៅចន្លោះ ១២០សង់ទីម៉ែត្រ ទៅ ២០០សង់ទីម៉ែត្រ
- ត្រូវមានបីសំរាប់ជំនួសគ្នាក្នុងដំណើរការ

## ១.៥ បញ្ហាសុខភាព

ដើម្បីការពារគ្រោះថ្នាក់ពីការចំលងរោគតាមខ្យល់និងធូលី អ្នកធ្វើការដែលទាក់ទងនឹងផ្នែកដឹកជញ្ជូនសំណល់ កាត់ ច្រោះ និងរែងត្រូវរៀបចំអោយមានពាក់ម៉ាស់ត្រឹមត្រូវ និងជាអនុសាសន៍បន្ទប់បញ្ជាគ្រឿងចក្រត្រូវបិទឱ្យជិត។

ឧបសម្ព័ន្ធ ១០: ប្រភេទសំណល់វេជ្ជសាស្ត្រ

| លរ | ប្រភេទ និងឈ្មោះសំណល់ | ប្រភេទសំណល់ | | |
|---|---|---|---|---|
| | | ក | ខ | គ |
| ១ | **សំណល់ស្រដៀងសំណល់ផ្ទះបាយ** | | | |
| | - សំណល់អាហារ | x | | |
| | - សំណល់ក្រដាសកាសែត | x | | |
| | - សំណល់ក្រដាសសំបុត្រផ្សេងៗ | x | | |
| | - សំណល់ក្រដាសឯកសារផ្សេងៗ | x | | |
| | - សំណល់វេចខ្ចប់ | x | | |
| | - សំណល់កាតុង | x | | |
| | - សំណល់ប្លាស្ទិក | x | | |
| | - សំណល់វេចខ្ចប់អាហារ | x | | |
| | - សំណល់កំប៉ុង | x | | |
| | - សំណល់បៃតង | x | | |
| ២ | **សំណល់មុតស្រួច** | | | |
| | - សំណល់សេរាំង | | x | |
| | - សំណល់ម្ជុលចាក់ថ្នាំ | | x | |
| | - សំណល់ស្កាវែន | | x | |
| | - សំណល់កាតេទ័រ (cateter) | | x | |
| | - សំណល់ម្ជុលដេររបួស | | x | |
| | - សំណល់កាំបិតវះកាត់ | | x | |
| | - សំណល់មុតស្រួចផ្សេងៗទៀត | | x | |
| ៣ | **សំណល់ពីផ្នែកសេវាកម្មវះកាត់ និងសម្ភព** | | | |
| | - សំណល់សំលៀកបំពាក់វះកាត់ | | | x |
| | - សំណល់ដុំសំឡី | | | x |
| | - សំណល់ប្លាស្ទ័រ និងបង់រុំ (plaster) | | | x |

| | | | | |
|---|---|---|---|---|
| | - សំណល់បង់លាងរបួស | | | x |
| | - សំណល់ស្រោមដៃ | | | x |
| | - សំណល់ឈាម | | | x |
| | - សំណល់ទឹកនោម | | | x |
| | - សំណល់លាមក | | | x |
| | - សំណល់សរីរាង្គ | | | x |
| | - សំណល់អវៈយវៈ | | | x |
| | - សំណល់សុក | | | x |
| | - សំណល់អំប្រ៊ុយយ៉ុង និងសាកសពកូនក្មេង | | | x |
| | - សំណល់អ្នកជំងឺប្រើប្រាស់ | | | x |
| | - កន្ទោរ | | | x |
| | - សំណល់ផ្តោកដាក់ទឹកនោម | | | x |
| | - សំណល់ប្រកបដោយគ្រោះថ្នាក់ផ្សេងទៀត | | | x |
| ៤ | **សំណល់មន្ទីរពិសោធន៍** | | | |
| | - សំណល់ឈាម | | | x |
| | - សំណល់ផ្តោកឈាម | | | x |
| | - សំណល់អតិសុខុមប្រាណ | | | x |
| | - សំណល់ជលិកា | | | x |
| | - សំណល់ប្រកបដោយគ្រោះថ្នាក់ផ្សេងទៀត | | | x |
| ៥ | **សំណល់ឱសថស្ថាន** | | | |
| | - សំណល់ថ្នាំហួសកាលបរិច្ឆេទ | | | x |
| | - សំណល់ថ្នាំហួសកាលបរិច្ឆេទដែលបញ្ជូនពីផ្នែកផ្សេងៗ | | | x |
| | - សំណល់វ៉ាក់សាំង | | | x |
| | - សំណល់សេរ៉ូម | | | x |
| | - សំណល់ស៊ីតូតូស៊ិក (cytitoxic) | | | x |

| | | | | |
|---|---|---|---|---|
| | - សំណល់ប្រកបដោយគ្រោះថ្នាក់ផ្សេងទៀត | | | x |
| ៦ | **សំណល់សារធាតុវិទ្យុសកម្ម** | | | |
| | - សំណល់សារធាតុវិទ្យុសកម្ម រួមទាំង រឹង រាវ និងឧស្ម័នដែលប្រើប្រាស់ក្នុងសកម្មភាពស្រាវជ្រាវអមវេជ្ជសាស្ត្រ និងសំភារៈមានផ្ទុកសារធាតុវិទ្យុសកម្ម | | | x |
| ៧ | **សំណល់គីមី** | | | |
| | - សំណល់សារធាតុគីមីរួមទាំង រឹង រាវ និងឧស្ម័នដែលប្រើប្រាស់ក្នុងសកម្មភាពស្រាវជ្រាវអមវេជ្ជសាស្ត្រ និងសំភារៈមានផ្ទុកសារធាតុគីមី | | | x |
| | - សារធាតុគីមីពុល | | | x |
| | - សារធាតុអាស៊ីត និងបាស | | | x |
| | - សារធាតុឆេះ | | | x |
| | - សារធាតុរេអាក់ទីវ (reactive) | | | x |

ឧបសម្ព័ន្ធ ១១

# បែបបទការដឹកជញ្ជូននិងការចាក់ចោលសំណល់វេជ្ជសាស្ត្រ

លេខរៀង:........................................

យោង:..........................................

| | ម្ចាស់សំណល់ | ក្រុមហ៊ុនប្រមូលនិងដឹកជញ្ជូន | អ្នកទទួល |
|---|---|---|---|
| ឈ្មោះក្រុមហ៊ុន | | | |
| អ្នកទំនាក់ទំនង | | | |
| អាសយដ្ឋាន | | | |
| លេខទូរស័ព្ទនិងហ្វាក់ | | | |
| អ៊ីមែល | | | |

រៀបរាប់អំពីសំណល់

| លរ | សំណល់ | បរិមាណសំណល់ គិតជាគោន | ប្រភេទសំណល់ | | |
|---|---|---|---|---|---|
| | | | ក | ខ | គ |
| ១ | | | | | |
| ២ | | | | | |
| ៣ | | | | | |
| ៤ | | | | | |
| ៥ | | | | | |
| ៦ | | | | | |
| ៧ | | | | | |

| | ម្ចាស់សំណល់ | អ្នកប្រមូលនិងដឹកជញ្ជូនសំណល់ | អ្នកទទួល |
|---|---|---|---|
| ថ្ងៃ ខែ ឆ្នាំ | .................................... | .................................... | .................................... |
| ហត្ថលេខា | .................................... | .................................... | .................................... |
| ឈ្មោះនិងតួនាទី | .................................... | .................................... | .................................... |